# នៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង (ក្រុមប្រឹក្សាជំនុំជម្រះពិសេស)

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Oct-2014, 09:58
CMS/CFO: Ly Bunloung

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងជំទាស់ឯកសិទ្ធិរបស់ នួន ជា

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **ក្រុមប្រឹក្សាជំនុំជម្រះពិសេស៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម ធូ មុណី ជាប្រធាន | នួន ជា |
| Nicholas KOUMJIAN | ចៅក្រម Rowan DOWNING | ខៀវ សំផន |
| | ចៅក្រម ហួត វុទ្ធី | **មេធាវីការពារក្តី៖** |
| | ចៅក្រម Chang-ho CHUNG | សុន អរុណ |
| | ចៅក្រម ប៉ែន ពេជ្រសាលី | Victor KOPPE |
| | | គង់ សំអុន |
| | | Arthur VERCKEN |

01034189



<u>ចម្លងជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

Anta GUISSÉ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា បានដាក់បណ្តឹងជំទាស់ចំពោះចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា ("បណ្តឹងជំទាស់")[1] ដោយចោទប្រកាន់ថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម យូរ ឧត្តរា ("ចៅក្រមជាតិ") មិនមានឯករាជ្យភាព មានផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងរឿងក្តី ០០២/០២ និងការស្តែងចេញនូវភាពលម្អៀង។ លើសពីនេះទៀត នួន ជា ក៏ស្នើសុំប្តឹងជំទាស់ ចៅក្រម Jean-Marc Lavergne (រួមគ្នាហៅថា "ចៅក្រម") ដោយចោទប្រកាន់ពីការស្តែងចេញនូវភាពលម្អៀង[2]។

2. សហព្រះរាជអាជ្ញាសូមឆ្លើយតបថា បណ្តឹងជំទាស់នេះគួរត្រូវបានច្រានចោលភ្លាមៗ។ នួន ជា មិនបានបង្ហាញឱ្យឃើញពីការលម្អៀងជាក់ស្តែង ឬការព្រួយបារម្ភដោយសមហេតុផលអំពីការលម្អៀងរបស់ចៅក្រមដែលពាក់ព័ន្ធឡើយ។ ភាគច្រើននៃបណ្តឹងជំទាស់គ្រាន់តែលើកពីការតវ៉ារបស់ នួន ជា ថាគាត់មិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ដែលជាការតវ៉ាដែលគាត់មានសិទ្ធិដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងបណ្តឹងសាទុក្ខ តែមិនសមស្របទាល់តែសោះសម្រាប់បណ្តឹងជំទាស់ចៅក្រមឡើយ។ ការតវ៉ាជាច្រើនរបស់ នួន ជា គ្រាន់តែជាការព្យាយាមលើកតវ៉ាឡើងវិញអំពីសារណាលើកមុនៗរបស់មេធាវីការពារក្តី ដែលត្រូវបានបិទផ្លូវតវ៉ារួចហើយ ហើយត្រូវបានអង្គជំនុំជម្រះសាលាដំបូងច្រានចោលតាំងពីយូរមកហើយ។ ការតវ៉ាផ្សេងៗទៀតដែលមាននៅក្នុងបណ្តឹងនេះ ដូចដែលបង្ហាញនៅផ្នែកខាងក្រោម ផ្អែកលើការកំណត់អង្គហេតុ និងការអនុវត្តអង្គច្បាប់ដោយមិនត្រឹមត្រូវ។ បណ្តឹងជំទាស់គ្រាន់តែជាយុទ្ធសាស្ត្រមួយនៅក្នុងយុទ្ធសាស្ត្រមិនស្របច្បាប់ដែលមានតាំងពីយូរណាស់មកហើយរបស់ នួន ជា ក្នុងការធ្វើឱ្យប៉ះពាល់ដល់ អ.វ.ត.ក ជាស្ថាប័ន ជាជាងការតវ៉ាទៅនឹងភស្តុតាងដ៏ច្រើនលើសលប់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់។

---

[1] ឯកសារ E314/4 សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រម ដើម្បី ពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់, ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤។

[2] ឯកសារ E314/6 បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា, ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("បណ្តឹងជំទាស់")។

## II. ច្បាប់ជាធរមាន

3. វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា "ភាគីអាចធ្វើបណ្ដឹងជំទាស់ចំពោះសហចៅក្រម ក្នុងករណីណាមួយ[...] មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង"[3]។ អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បណ្ដឹងបែបនេះ "ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និង ត្រូវមានភស្តុតាងបញ្ជាក់ផងដែរ"[4]។

### ១. ការសន្និដ្ឋានពីភាពមិនលម្អៀងរបស់ចៅក្រម ដោយមិនគិតអំពីប្រភេទនៃការលម្អៀងដែលបានចោទប្រកាន់

4. អ.វ.ត.ក បានអនុម័តយកយុត្តិសាស្ត្រអន្តរជាតិដែលចែងថា ចំណុចចាប់ផ្ដើមសម្រាប់ការសម្រេចថាតើ មានមូលដ្ឋានដែរឬទេ ក្នុងការប្ដឹងជំទាស់ចៅក្រមចេញពីសំណុំរឿងមួយ គឺការសន្និដ្ឋានអំពីភាពមិនលម្អៀងរបស់ចៅក្រម[5]។ ការសន្និដ្ឋានអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម គឺផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិសម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ[6]។ ភាគីដែលប្ដឹងជំទាស់មានបន្ទុកត្រូវបង្ហាញផ្ទុយពីការសន្និដ្ឋាននេះ ដែលជាលក្ខខណ្ឌកម្រិតខ្ពស់តម្រូវឲ្យបំពេញ[7]។

---

[3] វិធានផ្ទៃក្នុង ៣៤(២)។

[4] វិធានផ្ទៃក្នុង ៣៤(៣។

[5] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្ដឹងជំទាស់ចំពោះចៅក្រម និល ណុន ចៅក្រម Silvia Cartwright ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម ធូ មណី, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ឆ្នាំ ២០១១ លេខ E55/4") កថាខណ្ឌ ១២។

[6] ដូចជើងទំព័រខាងលើ។

[7] ដូចជើងទំព័រខាងលើ។

5. អ.វ.ត.ក បានអនុម័តយកលក្ខណវិនិច្ឆ័យ ដែលប្រើប្រាស់ដោយតុលាការអន្តរជាតិដទៃទៀត[8] ដែលតាមលក្ខណៈវិនិច្ឆ័យនេះ លក្ខខណ្ឌតម្រូវអំពីភាពមិនលម្អៀងត្រូវបានរំលោភ មិនមែនចាំបាច់តែថាចៅក្រមនោះមានភាពលម្អៀងជាក់ស្តែងនោះទេ ("*ភាពលម្អៀងអត្តនោម័ត*") ប៉ុន្តែក៏ក្នុងករណីមានការស្តែងចេញនូវភាពលម្អៀងដែរ ("*ភាពលម្អៀងសត្យានុម័ត*")[9]។

6. ការស្តែងចេញនូវភាពលម្អៀង ត្រូវបានបង្ហាញក្នុងករណីដែល (ក) ចៅក្រមគឺជាភាគីនៃរឿងក្តី ឬក៏មានផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍បុគ្គល នៅក្នុងលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រម នឹងនាំទៅដល់ការលើកកម្ពស់ដល់បុព្វហេតុ ដែលចៅក្រមរូបនោះបានចូលរួមពាក់ព័ន្ធ ឬ (ខ) កាលៈទេសៈដែលនាំឲ្យអ្នកសង្កេតដែលមានហេតុផល ហើយដែលទទួលបានព័ត៌មានត្រឹមត្រូវ អាចយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង[10]។ "អ្នកសង្កេតដោយមានហេតុផល" គឺជាបុគ្គលសម្មតិកម្ម ដែលមានគំនិតយុត្តិធម៌ ហើយមានការយល់ដឹងគ្រប់គ្រាន់អំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការវិនិច្ឆ័យដោយសមហេតុផលទៅលើចំណុចថាតើចៅក្រមដែលរងបណ្តឹងអាច ឬមិនអាចពិចារណាដោយមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យចំពោះបញ្ហាដែលបានកើតឡើងនៅក្នុងរឿងក្តី[11]។ ជាផ្នែកនៃការយល់ដឹងនេះ អ្នកសង្កេតដោយមានហេតុផល ត្រូវចាត់ទុកថាបានដឹងអំពីទំនៀមទម្លាប់នៃសុច្ចរិតភាព និងភាពមិនលម្អៀងរបស់ចៅក្រម ព្រមទាំងបានដឹងអំពីចំណុចដែលថាការមិនលម្អៀងគឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចផ្សេងៗដែលចៅក្រមបានធ្វើសច្ចា ប្រណិធាន

---

[8] *វណ្ណអាជ្ញា តទល់នឹង Anto Furundžija,* រឿងក្តីលេខ IT -95-17/I-A, សាលដីកា (អង្គជំនុំជម្រះតុលាការកំពូល តុលាការ ICTY), ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ (*"សាលដីកា អង្គជំនុំជម្រះតុលាការកំពូល រឿងក្តី Furundžija"*) នៅត្រង់កថាខណ្ឌ 189

[9] ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម ឆ្នាំ ២០១១, *ជើងទំព័រខាងលើលេខ ៥* នៅត្រង់កថាខណ្ឌ ១១។

[10] *ដូចជើងទំព័រខាងលើ សាលដីកា អង្គជំនុំជម្រះតុលាការកំពូល រឿងក្តី Furundžija, ជើងទំព័រខាងលើ លេខ ៩* នៅត្រង់កថាខណ្ឌ ១៨; *វណ្ណអាជ្ញា តទល់នឹង Abdallah Banda Abakaer Nourain and Saleh Mohammed Jerbo Jamus*, ICC Doc. No. ICC-02/05-03/09-344-Anx សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គរបស់ចៅក្រមលើ "បណ្តឹងជំទាស់របស់មេធាវីការពារក្តី ចំពោះចៅក្រម" ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២, ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ នៅត្រង់កថាខណ្ឌ ២០។

[11] *វណ្ណអាជ្ញា តទល់នឹង Radoslav Brđanin and Momir Talić,* រឿងក្តី លេខ IT-99-36-PT សេចក្តីសម្រេចលើបណ្តឹងរបស់ Momir Talić ប្តឹងជំទាស់ចៅក្រម និងសុំឲ្យដកចៅក្រម (អង្គជំនុំជម្រះសាលាដំបូង ២ របស់តុលាការ ICTY), ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ ("*សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ Talić*") នៅត្រង់កថាខណ្ឌ ១៥។

ថាត្រូវតែប្រកាន់ឱ្យបាន[12]។ តុលាការកំពូលសហរដ្ឋអាមេរិកបានសម្រេចថែមទៀតថា "ការបង្ហាញពីការមិនអត់ធ្មត់ ការមិនពេញចិត្ត ការធុញទ្រាន់ និងសូម្បីតែការបង្ហាញពីកំហឹង" មិនបង្ហាញថាជាការលម្អៀងបានដែរ[13]។

**ខ.ចៅក្រមអាចស្តាប់យ៉ាងត្រឹមត្រូវនូវរឿងក្តីច្រើន ដែលលើកឡើងពីបញ្ហាអង្គហេតុ ឬអង្គច្បាប់តែមួយ។ សក្តានុពលនៃការសម្រេចដែលធ្វើឱ្យមានការប៉ះពាល់នៅពេលអនាគតនោះ មិនអាចបង្កជាភាពលម្អៀងបានឡើយ**

7. យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់ស្របគ្នាថា ចៅក្រមមិនត្រូវបានហាមឃាត់មិនឱ្យចូលរួម ក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌពីរដាច់ដោយឡែកពីគ្នា ដែលកើតចេញពីបណ្តុំនៃហេតុការណ៍ដូចគ្នាឡើយ បើទោះបីជារឿងក្តីទាំងនោះពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ ឬអង្គច្បាប់ជាន់គ្នាក៏ដោយ[14]។ ក្នុងរឿងក្តី *Galić* ការិយាល័យរបស់តុលាការ ICTY បានដោះស្រាយលើបញ្ហានៃសមត្ថភាពរបស់ចៅក្រមក្នុងការចូលរួមក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌពីរ ឬក៏ច្រើន ដែលកើតចេញពីហេតុការណ៍ដូចៗគ្នា៖

> ការបណ្តុះបណ្តាល និងបទពិសោធន៍អាជីពរបស់ចៅក្រម បានធ្វើឱ្យពួកគាត់មានសមត្ថភាពក្នុងការពិចារណាតែបណ្តាភស្តុតាងណាដែលបានបង្ហាញនៅក្នុងសវនាការ មិនយកភស្តុតាងនៅក្នុងចិត្តរបស់គាត់ នៅពេលចេញសាលក្រម។ ចៅក្រមដែលមានតួនាទីជាអ្នកស្វែងរកការពិត ប្រហែលជាជួបប្រទះញឹកញាប់នូវព័ត៌មានអំពីរឿងក្តីនៅចំពោះមុខពួកគាត់ តាមរយៈបណ្តាញសារព័ត៌មាន ឬក្នុងករណីខ្លះតាមរយៈការជំនុំជម្រះដែលមានទំនាក់ទំនងគ្នា។ ការិយាល័យរបស់តុលាការ ICTY យល់ឃើញថាចៅក្រមមិនគួរត្រូវបានប្តឹងជំទាស់ ដោយគ្រាន់តែដោយសារការជួបប្រទះបែបនេះឡើយ [...]។ ការតម្រូវឱ្យចេញសាលក្រមដោយមានសំអាងហេតុ ដែលពន្យល់ពីមូលដ្ឋាននៃការយល់ឃើញរបស់

---

[12] *សាលដីកា អង្គជំនុំជម្រះតុលាការកំពូល រឿងក្តី* Furundžija, *ជើងទំព័រខាងលើ លេខ ៩* នៅត្រង់កថាខណ្ឌ ១៩០។

[13] រឿងក្តី *Liteky* និងអ្នកដទៃទៀត តទល់នឹង សហរដ្ឋអាមេរិក, 510 U.S. 540 (តុលាការកំពូល សហរដ្ឋអាមេរិក) ("រឿងក្តី *Liteky និងអ្នកដទៃទៀត*") នៅត្រង់ទំព័រ ៥៥៥-៥៥៦។

[14] ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់ ឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១៥; *សូមមើល រដ្ឋអាជ្ញា តទល់នឹង Sesay* និងអ្នកដទៃទៀត, SCSL-04-15-T, សេចក្តីសម្រេចលើញត្តិរបស់ Sesay និង Gbao ស្នើសុំឱ្យចៅក្រម Hon. Justice Bankole Thompson ដកខ្លួនចេញដោយស្ម័គ្រចិត្ត ឬដោយបណ្តឹងជំទាស់ ចេញពីរឿងក្តី RUF, (អង្គជំនុំជម្រះសាលាដំបូង I), ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ នៅត្រង់កថាខណ្ឌ ៥៥។

ចៅក្រម មានន័យថា ចៅក្រមរបស់តុលាការ ត្រូវបានបង្ខំឱ្យកម្រិតកំណត់ខ្លួនគាត់តែត្រឹមភស្តុតាងក្នុងកំណត់ត្រាប៉ុណ្ណោះ នៅពេលធ្វើការសម្រេចលើសេចក្ដីសន្និដ្ឋានរបស់ខ្លួន[15]។

8. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា បញ្ហាដែលចាំបាច់ត្រូវដោះស្រាយគឺថាតើ ចៅក្រមនឹងអាចវិនិច្ឆ័យលើបញ្ហាដែលត្រូវបានលើកឡើងក្នុងរឿងក្ដី ដោយមិនលម្អៀង និងដោយមិនមានបុរេវិនិច្ឆ័យបានដែរឬយ៉ាងណា[16]។ នៅក្នុងចម្លើយតបចំពោះបណ្ដឹងជំទាស់ចៅក្រម ក្នុងរឿងក្ដី *Šešelj* ប្រធានតុលាការ ICTY បានបញ្ជាក់ថា ចៅក្រមអាចត្រូវបានរំពឹងថាធ្វើការវិនិច្ឆ័យរឿងក្ដីរបស់ខ្លួន តែទៅលើភស្តុតាងដែលនៅចំពោះខ្លួនតែប៉ុណ្ណោះ ដោយមិនពិចារណាទៅលើការចោទប្រកាន់នានាដែលបានធ្វើឡើងក្នុងរឿងក្ដីផ្សេងៗ ដែលអាចមានឥទ្ធិពលព្យសនកម្មទៅលើជនជាប់ចោទឡើយ[17]។

9. តុលាការក្នុងស្រុក តុលាការថ្នាក់តំបន់ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុម័តយកទស្សនៈដែលថា ត្រឹមតែ "ការរំពឹងទុក" ដែលថាចៅក្រមអាចសម្រេចលើបញ្ហានៅក្នុងរឿងក្ដីជាក់លាក់មួយ ប្រឆាំងទៅនឹងភាគីមួយ មិនមែនជាមូលដ្ឋានក្នុងការប្ដឹងជំទាស់ចៅក្រមនោះទេ[18] បើទោះបីជាក្នុងករណីដែលការរំពឹងទុកនោះ ត្រូវបានបង្កើតឡើងដោយសារការសម្រេចលើកមុនរបស់ចៅក្រម ទៅលើបញ្ហាអង្គហេតុ ឬអង្គច្បាប់ក៏ដោយ[19]។ ដូចដែលបានសម្រេចដោយតុលាការជាន់ខ្ពស់របស់អូស្ត្រាលី៖

> ជាការចាំបាច់ដែលត្រូវនិយាយឱ្យបានច្បាស់លាស់ និងឮខ្លាំងៗថា មូលដ្ឋាននៃការប្ដឹងជំទាស់ចៅក្រមគឺជាការយល់ឃើញដោយសមហេតុផលថា មន្ត្រីតុលាការនឹងមិនសម្រេចទៅលើរឿងក្ដី ដោយអនាគតិ និងមិនមានការរើសអើង ជាជាងការបង្ហាញថាគាត់នឹងសម្រេចរឿងក្ដីប្រឆាំងទៅនឹងភាគីមួយ។ អាចនឹងមានស្ថានភាពជាច្រើនដែលសេចក្ដីសម្រេចលើកមុនរបស់មន្ត្រីតុលាការទៅលើបញ្ហាអង្គហេតុ ឬអង្គច្បាប់អាចបង្កើតជាការរំពឹងទុកមួយដែលថា គាត់ប្រហែលជានឹងសម្រេចទៅលើបញ្ហានានា នៅក្នុងរឿងក្ដី

---

[15] *រដ្ឋអាជ្ញា តទល់នឹង Galić*, រឿងក្ដី លេខ IT-98-29-T សេចក្ដីសម្រេចលើសារណារបស់ Galić អនុលោមតាមវិធាន ១៥(ខ) (ការិយាល័យតុលាការ ICTY), ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣ នៅត្រង់កថាខណ្ឌ ១៦។

[16] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ឆ្នាំ ២០១១, *ដើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១៥។

[17] *រដ្ឋអាជ្ញា តទល់នឹង Šešelj*, រឿងក្ដី លេខ IT-03-67-PT, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ (ប្រធាន), ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧, នៅត្រង់កថាខណ្ឌ ២៥។

[18] *Re J.R.L.; Ex parte C.J.L.* (1986), តុលាការជាន់ខ្ពស់អូស្ត្រាលី, 161 CRL 352 ("*Re J.R.L.*") នៅត្រង់ទំព័រ ៣៥២។

[19] ដូចជើងទំព័រខាងលើ

ជាក់លាក់មួយ ប្រឆាំងទៅនឹងភាគីមួយ។ ប៉ុន្តែ នេះមិនមានន័យថា គាត់នឹងដោះស្រាយបញ្ហាក្នុងរឿងក្តីនោះ ដោយមិនលម្អៀង និងដោយមិនមានបុរេវិនិច្ឆ័យឡើយ[20]។

10. ឃ្លានេះត្រូវបានដកស្រង់ដោយមានការយល់ព្រម ដោយតុលាការជាច្រើន *រួមទាំង* តុលាការធម្មនុញ្ញរបស់ប្រទេសអាហ្វ្រិកខាងត្បូង[21] តុលាការ ICTR ក្នុងរឿងក្តី *Karemera*[22] និងតុលាការ ICTY ក្នុងរឿងក្តី *Delalić* និងអ្នកដទៃទៀត ("រឿងក្តី *Čelebići*")[23] និងរឿងក្តី *Brđanin* និង *Talić*[24]។ ក្នុងរឿងក្តី *Karemera* តុលាការ ICTR បានបន្តអភិវឌ្ឍន៍គោលការណ៍នេះបន្ថែមទៀត ដោយថែងថា៖

> អ្វីដែលត្រូវបង្ហាញគឺថា សេចក្តីសម្រេចត្រូវតែ ឬគួរតែបានយល់ដឹងដោយសមហេតុថា ជាលទ្ធផលនៃការសន្មតទុកមុនប្រឆាំងនឹងម្ចាស់បណ្តឹង ហើយមិនទាក់ទងទៅនឹងការអនុវត្តច្បាប់ ដែលច្បាប់នេះអាចមានលទ្ធភាពបកស្រាយច្រើន ឬការវាយតម្លៃលើអង្គហេតុពាក់ព័ន្ធ[25]។

11. តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សបានសម្រេចថា "ចំណុចគ្រាន់តែថា ចៅក្រមជំនុំជម្រះបានចេញសេចក្តីសម្រេចលើកមុន ពាក់ព័ន្ធបទល្មើសតែមួយ មិនអាចចាត់ទុកថា អង្គហេតុនេះអាចធ្វើជាយុត្តិកម្មចំពោះការព្រួយបារម្ភណ៍ពីអនាគតិរបស់ចៅក្រមនោះបានឡើយ"[26]។ ហេតុដូច្នេះ បញ្ហាមិនមែនថា តើចៅក្រមប្រហែលជានឹងសម្រេចទៅលើបញ្ហាដូចគ្នា ក្នុងលក្ខណៈដូចគ្នាតែមួយ ដូចទៅនឹងអ្វីដែលពួកគាត់បានសម្រេចនៅក្នុងសេចក្តីសម្រេចលើកមុននោះឡើយ ប៉ុន្តែបញ្ហាគឺថាតើចៅក្រមទាំងនោះ

---

[20] ដូចជើងទំព័រខាងលើ

[21] ប្រធានាធិបតីសាធារណរដ្ឋអាហ្វ្រិកខាងត្បូង តទល់នឹង សហព័ន្ធបាល់អោប អាហ្វ្រិកខាងត្បូង, សាលក្រមលើបណ្តឹងជំទាស់ចិត្ត, តុលាការធម្មនុញ្ញអាហ្វ្រិកខាងត្បូង, 1999 (7) BCLR 725 (CC) នៅត្រង់កថាខណ្ឌ ៤៦។

[22] *រដ្ឋអាជ្ញា តទល់នឹង* Edouard Karemera *និងអ្នកដទៃទៀត*, រឿងក្តី លេខ ICTR 98-44-T, សេចក្តីសម្រេចលើបណ្តឹងរបស់ Karemera ប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ (ការិយាល័យ តុលាការ ICTR), ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត របស់ *Karemera*") នៅត្រង់កថាខណ្ឌ ១០។

[23] *រដ្ឋអាជ្ញា តទល់នឹង Zejnil Delalić, Hazim Delić, Esad Landžo and Zdravko Mucić*, រឿងក្តី លេខ IT-96-21-A, សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល), ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ នៅត្រង់កថាខណ្ឌ ៧០៧។

[24] *សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់* Talić, *ជើងទំព័រខាងលើ លេខ ១១* នៅត្រង់កថាខណ្ឌ ១៨។

[25] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត របស់*Karemera*, *ជើងទំព័រខាងលើ លេខ ២២* នៅត្រង់កថាខណ្ឌ ១៣។

[26] *រឿងក្តី* Schwarzenberge*r តទល់នឹងប្រទេសអាល្លឺម៉ង់* បណ្តឹងលេខ 75737/01, សាលក្រម, តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ("សាលក្រម *Schwarzenberger*") នៅត្រង់កថាខណ្ឌ ៤២។

“ប្រើប្រាស់ការពិចារណាដែលមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យដែរឬទេ ដើម្បីដោះស្រាយបញ្ហានៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ”[27]។ ការសន្មតជាមុនចំពោះសេចក្ដីសម្រេចជាក់លាក់ នៅពេលដែលវាត្រូវបានបង្ហាញចេញតាមរយៈមតិរបស់ចៅក្រមនោះ មិនអាចចាត់ទុកជាភាពលម្អៀងទេ”[28]។

12. តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សក៏បានសម្រេចផងដែរថា ចៅក្រមត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងរឿងក្ដីព្រហ្មទណ្ឌពីរ ដែលកើតចេញពីបណ្ដុំអង្គហេតុតែមួយ លើកលែងតែសាលក្រមកន្លងមក មានសេចក្ដីសម្រេចដែល “ពិតជាបុរេវិនិច្ឆ័យចំពោះបញ្ហាពិរុទ្ធភាពរបស់ជនជាប់ចោទ”[29]។ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការប្ដឹងជំទាស់ បុរេវិនិច្ឆ័យបែបនេះចាំបាច់ត្រូវតែពាក់ព័ន្ធជាមួយការសម្រេច “ទៅលើលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់ចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ហើយ [...] ថាតើ ដោយលើសពីវិមតិសង្ស័យ ម្ចាស់បណ្ដឹងមានពិរុទ្ធភាពចំពោះការប្រព្រឹត្តិបទល្មើសបែបនោះដែរឬទេ”[30]។ ក្នុងករណីដែលតុលាការយល់ថាខ្លួនមិនធ្វើការប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទទេនោះ ការស្ដែងចេញនូវភាពលម្អៀងមិនត្រូវបានបង្ហាញឡើយ[31]។

### ៣. កំណត់ត្រានៃសេចក្ដីសម្រេចដែលធ្វើឱ្យមានការប៉ះពាល់ពីពេលកន្លងមក មានគ្រប់គ្រាន់ក្នុងការកំណត់ថាមានការលម្អៀងជាក់ស្ដែង ឬការស្ដែងចេញនូវភាពលម្អៀងឡើយ

13. ដើម្បីគាំទ្រដល់ការចោទប្រកាន់អំពីភាពលម្អៀង ដោយផ្អែកលើសេចក្ដីសម្រេចរបស់ចៅក្រម ចាំបាច់ត្រូវបង្ហាញថា សេចក្ដីសម្រេចនោះពិតជា ឬអាចត្រូវបានគេយល់ឃើញដោយសមហេតុផល ថាកើតចេញពីបុរេវិនិច្ឆ័យប្រឆាំងនឹងម្ចាស់បណ្ដឹង ហើយមិនទាក់ទងជាមួយការអនុវត្តច្បាប់ ឬការពិចារណា

---

[27] *សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់* Talić, *ជើងទំព័រខាងលើ លេខ ១១* នៅត្រង់កថាខណ្ឌ ១៩។

[28] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១៥។

[29] *Poppe* តទល់នឹងប្រទេសហុល្លង់ សាលក្រម ECHR *(32271/04)* ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ (“សាលក្រម រឿងក្ដី Poppe”) នៅត្រង់កថាខណ្ឌ ២៦។

[30] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ២៨ [ដោយមានការគូសបញ្ជាក់បន្ថែម]។

[31] សាលក្រម*Schwarzenberger*, ជើងទំព័រខាងលើ លេខ២៦ នៅត្រង់កថាខណ្ឌ ៤៣។

លើអង្គហេតុពាក់ព័ន្ធឡើយ[32]។ នៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តនៅតុលាការ ICTY មានការសម្រេចថា "ការសន្និដ្ឋានជាមុនពីភាពមិនលម្អៀងរបស់ចៅក្រម នៅពេលពិនិត្យលើភស្ដុតាងដែលទទួលបានពីកិច្ចដំណើរការនីតិវិធីលើកមុន ត្រូវអនុវត្ត ដោយមិនគិតអំពីថាតើ ចៅក្រមក្នុងពេលកន្លងមកបានវាយតម្លៃជាវិជ្ជមាន ឬអវិជ្ជមាន ទៅលើភាពអាចជឿជាក់បាននៃភស្ដុតាងនោះទេ"[33]។ ការដែលចៅក្រម "ក្នុងពេលកន្លងមកបានស្ដាប់សក្ខីកម្មរបស់សាក្សី ទាក់ទងនឹងអង្គហេតុតែមួយ ដែលជាបញ្ហាចោទក្នុងបណ្ដឹងសាទុក្ខ" ហើយបាន "ធ្វើការពិចារណាទៅលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ" មិនមែនជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្ដល់យុត្តិកម្មដល់ការប្ដឹងជំទាស់ចិត្តទេ"[34]។

## ៤. ចៅក្រមអាចចូលរួមជំនុំជម្រះក្នុងរឿងក្ដីបន្តបន្ទាប់គ្នា ទាក់ទងនឹងចុងចោទតែមួយ

14. ការបំបែកកិច្ចដំណើរការនីតិវិធីសម្រាប់សំណុំរឿង ០០២ បានបណ្ដាលឱ្យមានស្ថានភាព *ពិសេសប្លែកពីគេ (sui generis)*។ យុត្តិសាស្ត្រទាក់ទងនឹងចៅក្រមដែលបានចូលរួមជំនុំជម្រះក្នុងរឿងក្ដីកន្លងមកទៅលើអង្គហេតុពាក់ព័ន្ធ ដែលជនជាប់ចោទបច្ចុប្បន្ន មិនមានវត្តមានចូលរួម ឬមិនមានអ្នកតំណាង មិនសមស្របនោះឡើយ។ នៅក្នុងករណីបែបនេះ ចំណុចគ្រោះថ្នាក់នោះគឺនៅត្រង់ថា ចៅក្រមអាចធ្វើការសម្រេច ដោយមិនបានផ្ដល់ដល់ជនជាប់ចោទនូវសិទ្ធជំទាស់ទៅលើភស្ដុតាង និងការយល់ឃើញ។ ក៏ប៉ុន្តែ នួន ជា និង ខៀវ សំផន បានចូលរួមពេញលេញក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ ពួកគេមានឱកាសក្នុងការជំទាស់ទៅលើភស្ដុតាងទាំងអស់ ព្រមទាំងអាចលើកទឡ្ហីករណ៍ផ្ទាល់ខ្លួន មុនពេលដែលមានការសម្រេច។ សំណុំរឿង ០០២/០២ គ្រាន់តែជាការជំនុំជម្រះបន្ថែម ដែលកើតចេញពីផ្នែកផ្សេងៗនៃឯកសារចោទប្រកាន់តែមួយតែប៉ុណ្ណោះ។ ស្ថានភាពបែបនេះគឺប្រហាក់ប្រហែលនឹងស្ថានភាពដែលចៅក្រមស្ដាប់ការជំទាស់លើភាពមិនលម្អៀងនៃការស្ម័គ្រចិត្តសារ

---

[32] ឯកសារ E55/4 បណ្ដឹងជំទាស់ចិត្តឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ៥* សេចក្ដីសម្រេច នៅត្រង់កថាខណ្ឌ ១៣។ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តរបស់ *Karemera ជើងទំព័រខាងលើ លេខ*២៣ នៅត្រង់កថាខណ្ឌ ១៣; *Re J.R.L.,* ជើងទំព័រខាងលើ លេខ១៨ នៅត្រង់កថាខណ្ឌ *៣៥២*។

[33] រដ្ឋអាជ្ញា តទល់នឹង *Popović និងអ្នកដទៃទៀត*, រឿងក្ដី លេខ IT-05-88-A, សេចក្ដីសម្រេចលើបណ្ដឹង របស់ Drago Nikolić ប្ដឹងជំទាស់ចិត្ត ចៅក្រម Liu Daqun (ប្រធាន), ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១ ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្ត*Popović*") នៅត្រង់កថាខណ្ឌ ៣, ៧-៨, ១០, និង ១២។

[34] *ដូចជើងទំព័រខាងលើ*

ភាព។ ការដែលចៅក្រមក្នុងសវនាការបែបនេះ យល់ឃើញថា ការសារភាពនេះធ្វើឡើងដោយស្ម័គ្រចិត្ត នឹងមិនអាចរារាំងចៅក្រមរូបនេះមិនឱ្យចូលរួមក្នុងសវនាការ ដែលចៅក្រមនេះត្រូវសម្រេចអំពីតម្លៃដែលត្រូវផ្តល់ដល់ការសារភាពនេះទេ។

15. លើសពីនេះទៀត ការអនុវត្តជាទូទៅនៅតុលាការក្នុងស្រុកនោះគឺថា ចៅក្រមតែមួយចូលរួមជំនុំជម្រះរឿងក្តីជាច្រើនប្រឆាំងចុងចោទតែមួយ។ នៅក្នុងរឿងក្តី *Liteky និងអ្នកដទៃទៀត តទល់នឹង សហរដ្ឋអាមេរិក* តុលាការកំពូលបានសម្រេចថា "ត្រូវបានចាត់ទុកថាជាការធម្មតា និងសមស្របតាំងពីយូរណាស់មកហើយ ដែលចៅក្រមមួយរូបចូលរួមជំនុំជម្រះ [...] ក្នុងសវនាការបន្តបន្ទាប់គ្នា ទាក់ទងនឹងចុងចោទតែមួយ"[35]។ ហេតុដូច្នេះ ការយល់ឃើញកន្លងមករបស់ចៅក្រម ក្នុងរឿងក្តីផ្សេង តែទាក់ទងគ្នា ប្រឆាំងនឹងជនជាប់ចោទតែមួយ នឹងមិនបណ្តាលឱ្យមានការស្តែងចេញនូវភាពលម្អៀង ដែលតម្រូវឱ្យមានការប្តឹងជំទាស់ប្រឆាំងចៅក្រមឡើយ[36]។ ក្នុងរឿងក្តី *Illinois តទល់នឹង Jeffrey Vance* ជនជាប់ចោទ ត្រូវបានចោទប្រកាន់ថាមានថ្នាំបង្កឱ្យវង្វេងវង្វាយ (hallucinogen) ដោយខុសច្បាប់ ហើយនាពេលកន្លងមកត្រូវបានផ្តន្ទាទោសចំពោះបទចោទទាក់ទងគ្រឿងញៀន ដោយចៅក្រមជំនុំជម្រះតែមួយ។ តុលាការសម្រេចថា៖

> ជាទូទៅ ច្បាស់ណាស់ថា ការដែលចៅក្រមមួយរូបបានសម្រេចដោយធ្វើឱ្យមានការប៉ះពាល់ ប្រឆាំងនឹងជនជាប់ចោទម្នាក់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី នឹងមិនអាចប្តឹងជំទាស់ចៅក្រមរូបនោះមិនឱ្យចូលរួមក្នុងការជំនុំជម្រះបន្តបន្ទាប់ក្នុងរឿងក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលក្នុងរឿងក្តីនោះបុគ្គលដដែលគឺជាភាគីនៃរឿងក្តី [...] ឡើយ។ ការដែលថា ចៅក្រមមួយរូបជឿជាក់ថា ភស្តុតាងក្នុងរឿងក្តីមួយនាំឱ្យមានពិរុទ្ធភាពដល់ជនជាប់ចោទដោយហួសពីវិមតិសង្ស័យនោះ ហើយចៅក្រមបានសម្រេចបែបនេះ ពិតជាមិនអាចបង្ហាញថា ចៅក្រមរូបនេះមានបុរេវិនិច្ឆ័យប្រឆាំងនឹងជនជាប់ចោទនោះឡើយ[37]។

16. ប្រហាក់ប្រហែលគ្នានេះដែរ មានការសម្រេចថា ការដែលចៅក្រមមួយរូបបានចូលរួមជំនុំជម្រះក្នុងរឿងក្តីមួយ បន្ទាប់ពីសាលាឧទ្ធរណ៍បានបង្វិលរឿងក្តីនោះមកឱ្យធ្វើការជំនុំជម្រះជាថ្មីនោះ នឹងមិនអាច

[35] រឿងក្តី *Liteky* និងអ្នកដទៃទៀត, *ដើងទំព័រខាងលើ* លេខ ១៣ នៅត្រង់ទំព័រ ៥៥១។

[36] រឿងក្តី *Liteky* និងអ្នកដទៃទៀត, *ដើងទំព័រខាងលើ* លេខ ១៣ នៅត្រង់ទំព័រ ៥៥១។

[37] *People តទល់នឹង Vance*, 76 Ill.2d 171, 28 Ill.Dec. 508, 513, 390 N.E.2d 867, 872 (1979)។

ជាមូលដ្ឋានសម្រាប់ការប្តឹងជំទាស់ចៅក្រមឡើយ។ សាលាឧទ្ធរណ៍របស់សហរដ្ឋអាមេរិកបានសម្រេចថា "ការដែលចៅក្រមជំនុំជម្រះមួយរូបនៅក្នុងសវនាការពីដើម ក៏ជាចៅក្រមជំនុំជម្រះក្នុងសវនាការលើកទីពីរនោះ មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់បង្ហាញថាមានភាពលម្អៀង និងបុរេវិនិច្ឆ័យឡើយ"[38]។ ជាថ្មីម្តងទៀត នៅក្នុងរឿងក្តី *Welch តទល់នឹង The State* តុលាការកំពូលរដ្ឋ Georgia សម្រេចច្រានចោលទឡ្ហីករណ៍ដែលថា ចៅក្រមជំនុំជម្រះគួរត្រូវបានប្តឹងជំទាស់ចៅក្រម ដោយសារតែគាត់គឺជាចៅក្រមជំនុំជម្រះក្នុងសវនាការលើកមុនរបស់ជនជាប់ចោទ ដែលក្នុងសវនាការនេះ ចៅក្រមរូបនោះបានសម្រេចផ្តន្ទាទោសប្រហារជីវិតជនជាប់ចោទ[39]។

## III. **ទឡ្ហីករណ៍**

### ១. បញ្ហាបឋម

ក) បណ្តឹងសាទុក្ខបន្តផ្នែក និងបញ្ហាត្រូវបានដោះស្រាយរួចហើយ

17. បណ្តឹងជំទាស់ចៅក្រមមិនមែនជាមធ្យោបាយសមស្របសម្រាប់ការប្តឹងតវ៉ាឡើងវិញលើសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសំណុំរឿង០០២/០១ឡើយ។ នៅក្នុងបណ្តឹងជំទាស់ចៅក្រមទាំងមូល នួន ជា បានលើកយកបញ្ហាអង្គសេចក្តី ដែលគួរតែជាការបង្ហាញពីការស្វែងចេញនូវភាពលម្អៀង ដូចជា "ការមិនបើកចិត្តឱ្យទូលាយ" របស់ចៅក្រមចំពោះភស្តុតាង និងសារណាដែលដាក់ដោយមេធាវីការពារក្តី ការចោទប្រកាន់ពីកំហុសឆ្គងក្នុងសាលក្រមសំណុំរឿង ០០២/០១ ព្រមទាំងការពឹងផ្អែកហួសហេតុទៅលើសក្ខីកម្មរបស់អ្នកជំនាញ[40]។ បញ្ហាបែបនេះគួរតែត្រូវបានលើកឡើងក្នុងបណ្តឹងសាទុក្ខ ដែល នួន ជា ព្យាយាមធ្វើក្នុងពេលជាមួយគ្នា តាមរយៈការជូនដំណឹងពីបណ្តឹងសាទុក្ខរបស់

---

[38] *Poland តទល់នឹង Stewart*, [1997] 117 F.3d 1094, 97 Cal. Daily Op. Serv. 4854, 97, D.A.R. 7958. នៅត្រង់កថាខណ្ឌ ៦៥។

[39] *Welch* តទល់នឹង *The State*, 257 Ga. 197 (1987) 357 S.E.2d 70។

[40] ជាឧទាហរណ៍, សូមមើល ឯកសារ E314/6 បណ្តឹងជំទាស់ចៅក្រម, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៦១-៦៩, ១២៧, ១២៩-១៣៣។

គាត់[41] ឬក៏អាចចាត់ថាជាចេតនាប្ដឹងតវ៉ាឡើងវិញលើបណ្ដឹងជិតចិត្តកន្លងមក[42] ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចច្រានចោល ព្រមទាំងបិទផ្លូវតវ៉ារួចហើយ។ ការលើកឡើងនូវបញ្ហាបែបនេះម្ដងទៀតនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេស មិនត្រឹមតែមិនស៊ីសង្វាក់ជាមួយគោលការណ៍សេដ្ឋកិច្ចតុលាការប៉ុណ្ណោះទេ ថែមទាំងមិនស៊ីសង្វាក់ជាមួយឋានានុក្រមអង្គជំនុំជម្រះដែលត្រូវបានបង្កើតឡើងនៅក្នុង អ.វ.ត.ក ឡើយ។

ខ) បន្ទុកក្នុងការបង្ហាញភស្តុតាង និងបទដ្ឋានបង្ហាញភស្តុតាង

18. បន្ទុកក្នុងការបង្ហាញភស្តុតាងសម្រាប់រាល់បណ្ដឹងជិតចិត្ត គឺស្ថិតលើភាគីដែលដាក់បណ្ដឹង។ មានការកំណត់យ៉ាងច្បាស់លាស់ថា មានលក្ខខណ្ឌកម្រិតខ្ពស់ដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងការសន្មតទុកជាមុនពីភាពមិនលម្អៀង[43]។ នៅក្នុងរឿងក្ដី អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានបញ្ជាក់ថា ម្ចាស់បណ្ដឹងសាទុក្ខត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះអាចជឿជាក់ថា ចៅក្រមមួយរូបមានភាពលម្អៀងនៅក្នុងរឿងក្ដីរបស់គាត់ ហើយ "បណ្ដឹងជិតចិត្តគ្រាន់តែ

---

[41] ជាឧទាហរណ៍, សូមមើល E313/1/1 ការជូនដំណឹងពីបណ្ដឹងសាទុក្ខ ប្រឆាំងសាលក្រម ក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤, មូលដ្ឋាន ៦, ៣០, ៣៩ និង ២០០។

[42] នៅក្នុងឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត ឆ្នាំ ២០១១ ក្រុមប្រឹក្សាជំនុំជម្រះពិសេសមួយបានសម្រេចថា ការចូលរួមរបស់ ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Jean-Marc Laverge នៅក្នុងសំណុំរឿង ០០១ និងក្នុងសាលក្រមមិនអាចចាត់ទុកថាជា បុរេវិនិច្ឆ័យដែលអាចប្ដឹងជិតចិត្តចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ។ ដូច្នេះ ចេតនារបស់មេធាវីការពារក្ដី ក្នុងការប្ដឹងតវ៉ាឡើងវិញ លើបញ្ហានេះ គួរត្រូវបានរារាំង, ហើយកថាខណ្ឌ ១១៥-១២១ នៅក្នុងបណ្ដឹងរបស់មេធាវីការពារក្ដី គួរត្រូវបានច្រានចោល។ *សូមមើល* ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត, *ជើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១១៥-១២១។

[43] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត ឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១២។ សេចក្ដីសម្រេចលើ បណ្ដឹងរបស់សហមេធាវី ប្ដឹងជិតចិត្តបន្ទាន់ចំពោះចៅក្រម ន័យ ថុល ដែលរងចាំបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្ន ក្នុងសំណុំរឿង នួន ជា, C11/29, ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, នៅត្រង់កថាខណ្ឌ ៨។ សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត របស់ *Karemera*, *ជើងទំព័រខាងលើ លេខ* ២២ នៅត្រង់កថាខណ្ឌ ១០។

ត្រូវធ្វើឡើងតាមការបង្ហាញថា មានការយល់ឃើញសមហេតុផលអំពីភាពលម្អៀង តាមរយៈសំអាងហេតុនៃបុរេវិនិច្ឆ័យ ហើយការទាមទារត្រូវមានការបង្ហាញឱ្យបានច្បាស់លាស់”[44]។

19. នួន ជា បានលើកឡើងយ៉ាងត្រឹមត្រូវថា ដើម្បីបង្ហាញពីភាពលម្អៀងជាក់ស្តែង ភាគីដាក់បណ្តឹងត្រូវតែជំទាស់ទៅលើការសន្និតទុកជាមុនពីភាពមិនលម្អៀងរបស់ចៅក្រម[45]។ ប៉ុន្តែ គាត់បានលើកឡើងដោយមិនត្រឹមត្រូវលើអង្គច្បាប់ នៅពេលអះអាងថា ការសន្និតទុកជាមុនពីភាពមិនលម្អៀង មិនអនុវត្តបាននៅពេលការចោទប្រកាន់គឺជាការស្តែងចេញនូវភាពលម្អៀង ដែលខុសពីភាពលម្អៀងជាក់ស្តែង[46]។ នួន ជា បានយោងទៅសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL ដែលសម្រេចថា “លក្ខខណ្ឌសម្រាប់ការស្តែងចេញនូវភាពលម្អៀង មិនតម្រូវឱ្យបង្ហាញភស្តុតាងអំពីភាពលម្អៀងពិតប្រាកដទេ”[47] ហើយថា ប្រសិនបើមាន “សូចនាករមួយចំនួននៃភាពលម្អៀង ការសម្រេចដែលត្រឹមត្រូវ និងសមហេតុផលគឺថា ចៅក្រមត្រូវបញ្ឈប់ពីតួនាទី”[48]។ ផ្ទុយពីការអះអាងនេះនៅត្រង់កថាខណ្ឌ ១៩ (ជើងទំព័រ ២៤) នៃបណ្តឹងដិតចិត្ត អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL មិនបានលើកឡើងថា ការជំទាស់ទៅនឹងការសន្និតទុកជាមុនពីភាពមិនលម្អៀង មិនចាំបាច់ទេ នៅពេលដែលជំទាស់ទៅនឹងការស្តែងចេញនូវភាពលម្អៀងនោះ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃថាតើភាគីដាក់បណ្តឹងបានជំទាស់ដែរ ឬយ៉ាងណា ចំពោះការសន្និតទុកជាមុនពីភាពមិនលម្អៀង ហើយអង្គជំនុំជម្រះបានសន្និដ្ឋានថា មិនមានការស្តែងចេញនូវភាពលម្អៀងជាសត្យានុម័តឡើយ ដោយសារតែ*ម្ចាស់បណ្តឹងមិនបានជំទាស់ទៅលើការសន្និតទុកជាមុន* ហេតុដូច្នេះ អង្គជំនុំជម្រះ

[44] សាលដីកា រឿងក្តី *Furundžija, ជើងទំព័រខាងលើ លេខ* ៩ នៅត្រង់កថាខណ្ឌ ១៩៧; សូមមើលផងដែរ Mason J, in *Re J.R.L., ជើងទំព័រខាងលើ លេខ* ១៨ នៅត្រង់ទំព័រ ៣៥៣។ បន្តនៅក្នុង *Re Polities*; *Ex parte Hoyts Corporation Pty Ltd* (1991) 65 ALJR 444 នៅត្រង់ ៤៤៨។

[45] ឯកសារ E314/6 បណ្តឹងដិតចិត្ត, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១៩។

[46] *ដូចជើងទំព័រខាងលើ*។

[47] *ដូចជើងទំព័រខាងលើ* រដ្ឋអាជ្ញា តទល់នឹង *Sesay និងអ្នកដទៃទៀត*, SCSL-04-15-T, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Sesay, Kallon and Gbao ប្រឆាំង សេចក្តីសម្រេចលើញត្តិរបស់ Sesay and Gbao សុំឱ្យចៅក្រម Hon. Justice Bankole Thompson ដកខ្លួនចេញដោយស្ម័គ្រចិត្ត ឬដោយប្តឹងដិតចិត្ត ចេញពីរឿងក្តី RUF (អង្គជំនុំជម្រះតុលាការកំពូល), ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០០៨ នៅត្រង់កថាខណ្ឌ ៩, ១២-១៣។

[48] *ដូចជើងទំព័រខាងលើ*។

បានទទួលស្គាល់ថា បន្ទុកនៃការជំទាស់ទៅនឹងការសន្មតទុកជាមុនលើភាពមិនលម្អៀង ត្រូវអនុវត្តដូចគ្នា នៅពេលជំទាស់ទៅនឹងការស្តែងចេញនូវភាពលម្អៀងនោះ[49]។

## ២. នួន ជា មិនបានបំពេញតាមលក្ខខណ្ឌកម្រិតក្នុងការបង្ហាញពីភាពលម្អៀងជាក់ស្តែង ឬការយល់ឃើញពីភាពលម្អៀង

ក) នួន ជា មិនបានបង្ហាញពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ចៅក្រមជាតិ នៅក្នុងសំណុំរឿង ០០២/០២

20. នួន ជា បានជំទាស់ថា ចៅក្រមជាតិមាន "ផលប្រយោជន៍ផ្ទាល់ខ្លួន" នៅក្នុងសំណុំរឿង ប្រឆាំងនឹងគាត់[50] ដែលសារតែការចោទប្រកាន់ថា ចៅក្រមជាតិមួយរូប ឬច្រើនរូប មាន "បទពិសោធន៍ដោយផ្ទាល់លើបញ្ហានានាដែលមានភាពចម្រូងចម្រាស់ក្នុងសំណុំរឿង ០០២"[51] ដែលគាត់បានជំទាស់ថា បានបង្ហាញនូវការស្តែងចេញនូវភាពលម្អៀង ឬភាពលម្អៀងជាក់ស្តែង ដែលមិនអាចទទួលយកបាន ដែលដោយសារហេតុនេះហើយទើបត្រូវដកចេញពីក្នុងសំណុំរឿង ០០២/០២[52]។

21. ការចោទប្រកាន់របស់ នួន ជា អំពីភាពលម្អៀងជាបុគ្គលរបស់ចៅក្រមជាតិ កើតចេញពីមតិរបស់អតីតចៅក្រម Silvia Cartwright នៅវិទ្យាស្ថាន Aspen នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("មតិនៅវិទ្យាស្ថាន Aspen")[53] ដោយលោកស្រីបាននិយាយថា៖

a. ចៅក្រមជាតិមួយរូបដោយមិនបញ្ចេញឈ្មោះ ត្រូវបានចាប់ខ្លួនដោយភាន់ច្រឡំ ថាជាទាហាន លន់ នល់ នៅក្នុងទីក្រុងភ្នំពេញ ហើយត្រូវបានដោះលែងនៅពេលក្រោយ។ គាត់ធ្លាប់ធ្វើការ

---

[49] ឯកសារ E314/6 បណ្តឹងនិតចិត្ត, *ដើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១៤។

[50] *ដូចជើងទំព័រខាងលើ* នៅត្រង់ទំព័រ ១៦, ផ្នែក គ។

[51] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៥៤។

[52] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៥៣-៦០។

[53] ឯកសារ E305/12.38R, 'ការជំនុំជម្រះលើឧក្រិដ្ឋកម្មសាហាវព្រៃផ្សៃ៖ តុលាការខ្មែរក្រហម, យុត្តិធម៌អន្តរកាល និងនីតិរដ្ឋ" ឆ្នាំ ២០១៣ ("មតិនៅវិទ្យាស្ថាន Aspen")។

នៅទំនប់មួយ ដែលប្រធានទំនប់នោះ ក្រោយមកត្រូវបានចោទប្រកាន់ ហើយសម្លាប់ចោល នៅ ស ២១។ គាត់ក៏ជាជនរងគ្រោះនៃការរៀបការដោយបង្ខំ[54] និង

b. ចៅក្រមជាតិមួយរូបដោយមិនបញ្ចេញឈ្មោះ ត្រូវបានបញ្ជូនទៅធ្វើការងារនៅកងកុមារ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[55] (ដែលជារួមគឺ "បទពិសោធន៍ជនរងគ្រោះ")។

22. សហព្រះរាជអាជ្ញាមិនអាចឆ្លើយតបចំពោះភាពត្រឹមត្រូវនៃបទពិសោធន៍ជនរងគ្រោះ ដែលបង្ហាញដោយចៅក្រម Cartwright ឡើយ។ នួន ជា មិនបានផ្តល់ភស្តុតាងដោយផ្ទាល់ដើម្បីគាំទ្រដល់ការចោទប្រកាន់ដែលធ្វើឡើងហួសពីមតិរបស់ចៅក្រម Cartwright ឡើយ ហើយដូចដែលសហព្រះរាជអាជ្ញានឹងពិភាក្សានៅផ្នែកខាងក្រោម ដែលអាចចាត់ទុកថាត្រឹមជាការទាយស្មាន ដែល នួន ជា ទាញចេញពីដោយមិនត្រូវបរិបទប៉ុណ្ណោះ។ មិនមានការកំណត់ច្បាស់លាស់ពីទីកន្លែង ឬទីតាំងឧក្រិដ្ឋកម្ម ដើម្បីវាយតម្លៃថាតើ បទពិសោធន៍ជនរងគ្រោះណាមួយ ពិតជាបានកើតឡើងនៅទីតាំងដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរឬយ៉ាងណា (ក្រៅពីកាចោទប្រកាន់ពីការរៀបការដោយបង្ខំ ដែលត្រូវបានឮនៅទូទាំងប្រទេសទៅហើយ)។ ចៅក្រមជាតិដែលពាក់ព័ន្ធមិនត្រូវបានកំណត់អត្តសញ្ញាណឡើយ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាមិនអាចរកឃើញភស្តុតាងដែលថា បទពិសោធន៍ជនរងគ្រោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសំណុំរឿង ដែលភស្តុតាងទាំងអស់ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ត្រូវបានទាញចេញពីសំណុំរឿងនេះ។

23. បើទោះបីជាចៅក្រមគឺជាជនរងគ្រោះនៃអំពីដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ក៏ដោយក៏ នួន ជា បានយល់ស្របរួចទៅហើយថា បទពិសោធន៍បែបនេះមិនអាចនាំទៅដល់ការប្តឹងជំទាស់ដោយស្វ័យប្រវត្តិនោះឡើយ[56]។ ដើម្បីបង្ហាញថាចៅក្រមមិនមានចិត្តបើកទូលាយ ចាំបាច់ត្រូវតែបង្ហាញថាចៅក្រមរូបនោះមានបុរេវិនិច្ឆ័យ ឬការសម្រេចទុកជាមុនចំពោះសំណុំរឿង ០០២/០២

---

[54] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ*2 នៅត្រង់កថាខណ្ឌ ៥៣។

[55] *ដូចជើងទំព័រខាងលើ* ។

[56] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៥៤។

ប្រឆាំងនឹង នួន ជា "ដោយមិនយោងទៅរកការវាយតម្លៃលើភស្តុតាង ក្នុងករណីនីមួយៗនោះឡើយ"[57] ហើយចៅក្រមបែបនេះនឹងមាន "ការលំបាកក្នុងការអនុវត្តយុត្តិសាស្ត្របច្ចុប្បន្ន"[58] នៅក្នុងអង្គជំនុំជម្រះសាលាដំបូង។ មិនមានបញ្ហាបែបនេះទេនៅទីនេះទេ។

24. ចំពោះមតិនៅ Aspen នៅពេលធ្វើការពិនិត្យឡើងវិញទៅតាមបរិបទនៅជុំវិញ មិនបានបង្ហាញទាំងអំពីភាពលម្អៀងជាក់ស្តែង តាមរយៈផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ចៅក្រមជាតិ ព្រមទាំងមិនបានបង្ហាញពីការយល់ឃើញដោយសមហេតុផលអំពីភាពលម្អៀងឡើយ។ ពាក្យសម្តីរបស់ចៅក្រម Cartwright គ្រាន់តែឆ្លុះបញ្ចាំងពីការទាយស្មានផ្ទាល់ខ្លួនរបស់គាត់ អំពីគំនិត និងអារម្មណ៍ស្និទ្ធស្នាលរបស់សហការីគាត់ក្នុងក្រុមប្រឹក្សាជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ ហើយសម្លេង និងមតិទាំងនោះធ្វើឡើងជាភាសាខ្មែរ ដែលគាត់បានបញ្ជាក់ថា គាត់មិនអាចយល់បានក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ តាមពិតទៅ ពាក្យសម្តីរបស់ ចៅក្រម Cartwright គឺថា "ខ្ញុំមិនយល់ពីអ្វីដែលពួកគេកំពុងនិយាយទេ តែខ្ញុំអាចស្មានថាជាមតិយោបល់មិនគួរសមអំពីភស្តុតាងមួយចំនួន ហើយលោកអ្នកអាចស្តាប់ឮពួកគាត់បញ្ចេញសម្លេងបែបប្រឆាំងទៅនឹងចំណុចមួយចំនួន ដែលពួកគាត់បានស្តាប់[59]"។ ទោះជាក្នុងករណីណាក៏ដោយ ចៅក្រមមានសិទ្ធិមិនជឿជាក់ទៅលើភស្តុតាង។ ការបង្ហាញពីប្រតិកម្មបែបនេះទៅលើភស្តុតាង នឹងមិនបង្ហាញពីភាពលម្អៀងឡើយ។

25. ត្រឹមតែប្រតិកម្មពីក្រុមប្រឹក្សាជំនុំជម្រះ ដែលអាច ឬមិនអាចចាត់ទុកថាជាការបង្ហាញពីការមិនយល់ស្រប ឬក៏ការយល់ឃើញថាភស្តុតាងរបស់ភាគីមួយមិនអាចជឿជាក់បាននោះ មិនគ្រប់គ្រាន់ក្នុងការបំពេញបានតាមបទដ្ឋានដ៏ខ្ពស់នៃការបង្ហាញភស្តុតាងដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការបង្ហាញពីភាពលម្អៀងនោះទេ។ ដូចដែលតុលាការកំពូលសហរដ្ឋអាមេរិកបានសម្រេច "ការបង្ហាញពីការមិនអត់ធ្មត់

---

[57] រដ្ឋអាជ្ញា តទល់នឹង *Vojislav Šešelj,* រឿងក្តី IT-03-67-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់មេធាវីការពារក្តី ប្រឆាំងចៅក្រម Frederik Harhoff និងរបាយការណ៍ជូនអនុប្រធាន (អង្គជំនុំជម្រះតុលាការ ICTY ត្រូវបានកោះហៅ តាមដីកាបង្គាប់របស់អនុប្រធាន), ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៣ នៅត្រង់កថាខណ្ឌ ១៣។

[58] ដូចជើងទំព័រខាងលើ។

[59] មតិនៅវិទ្យាស្ថាន Aspen, *ជើងទំព័រខាងលើ លេខ* ៥៣ នៅត្រង់ 46:45។

ការមិនពេញចិត្ត និងសូម្បីតែការបង្ហាញពីកំហឹង” នឹងមិនអាចត្រូវបានកំណត់ថាជាការលម្មើងបាន ដែរ[60]។

26. បន្ទាប់មក មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ចៅក្រមជាតិបានបង្ហាញពី “ការឈឺចាប់” ដូចក្នុង រឿងក្តី *Kyprinaou* នៅក្នុងពេលជំនុំជម្រះលើសំណុំរឿង ០០២/០១ ដោយចៅក្រមបានផ្តល់ “យោបល់មិនគួរសម”[61] និង “សម្តែងទឹកមុខប្រឆាំង”[62] រួមជាមួយនឹងការមិនបើកចិត្តឱ្យទូលាយ ចំពោះភស្តុតាង និងសារណារបស់មេធាវីការពារក្តី[63]។ មតិដែលលើកឡើងដោយចៅក្រម Cartwright អាចបង្ហាញពីភាពខុសគ្នាយ៉ាងច្បាស់ពីរឿងក្តី *Kyprinaou*[64]។ នៅក្នុងរឿងក្តី *Kyprinaou* អង្គជំនុំជម្រះកំពូលនៃតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សយល់ឃើញថា ចៅក្រមនៅក្នុង តុលាការ Limassol Assize (ប្រទេស Cyprus) បាន “ចាត់ទុកថាជាការប្រមាថយ៉ាងធ្ងន់ធ្ងរទៅលើ ខ្លួន”[65] ហើយយល់ថា ការប្រព្រឹត្តិរបស់ *Kyprinaou* ដែលជាមេធាវី គឺជា “ការប្រមាថចំពោះ កិត្តិយសផ្ទាល់ខ្លួនរបស់ពួកគេ”[66] ដែលបង្ហាញតាមរយៈការដែលថាចៅក្រមបានចាត់ទុកការប្រព្រឹត្តិ របស់ *Kyprinaou* ថាជាការប្រមាថតុលាការ ហើយបញ្ជាក់ថា ការប្រព្រឹត្តិបែបនេះគឺ “ពិតជាមិន អាចទទួលយកបានទាល់តែសោះ” ហើយផ្តល់ឱកាសឱ្យ *Kyprinaou* ថ្លែងតែក្នុងគោលបំណង សម្រាលទៅលើការផ្តន្ទាទោសប៉ុណ្ណោះ មិនឱ្យធ្វើការឆ្លើយតបចំពោះការចោទប្រកាន់ពីការប្រមាថ តុលាការឡើយ[67]។ ការប៉ាន់ស្មានរបស់ចៅក្រម Cartwright បើទោះបីជាត្រឹមត្រូវក៏ដោយ ក៏នៅខុស គ្នាខ្លាំងណាស់ធៀបនឹងសម្លេង ព្រមទាំងខ្លឹមសារ ដែលជាបញ្ហាចោទនៅក្នុងរឿងក្តី *Kyprinaou*។

---

[60] រឿងក្តី *Liteky* និងអ្នកដទៃទៀត, ដើងទំព័រខាងលើ លេខ *១៣* នៅត្រង់ទំព័រ ៥៥៥។

[61] មតិនៅវិទ្យាស្ថាន Aspen, *ជើងទំព័រខាងលើ លេខ* ៥៣ នៅត្រង់ 46:45។

[62] ដូចជើងទំព័រខាងលើ។

[63] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៥៩។

[64] *Kyprianou* តទល់នឹង *Cyprus*, ECtHR, បណ្តឹងលេខ 73797/01, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥។

[65] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ៧៧។

[66] ដូចជើងទំព័រខាងលើ។

[67] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ៧៨។

27. ប្រសិនបើចៅក្រមជាតិត្រូវបានដកចេញ ក្នុងកាលៈទេសៈនេះមែននោះ ប្រាកដណាស់ថា សឹងតែមិនមានជនជាតិកម្ពុជាណាដែលនឹងមិនត្រូវបានប្ដឹងដិតចិត្តក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះ ហើយឥទ្ធិពលនេះនឹងធ្វើឱ្យ នួន ជា មាននិទណ្ឌភាពពីឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗ។ ប្រទេសកម្ពុជា ដែលជារដ្ឋភាគីនៃអនុសញ្ញាទីក្រុងហ្សឺណែវ[68] អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍[69] លក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ[70] និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលបង្កើតជាមូលដ្ឋានច្បាប់អន្តរជាតិសម្រាប់ការបង្កើតប្រតិបត្តិការរបស់ អ.វ.ត.ក ត្រូវមានកាតព្វកិច្ចក្នុងការជំនុំជម្រះ និងដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ ដូចជា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[71]។ នេះហាក់ដូចជាអ្វីដែលជាគោលដៅដែល នួន ជា ព្យាយាមសម្រេចឱ្យបាន ដែលជាសេចក្ដីប្រកាសព័ត៌មានរបស់តុលាការដែលថា គ្មាននរណាម្នាក់ក្នុងចំណោម "ប្រជាជនកម្ពុជា និងយុវជនខ្មែរជាទីស្រឡាញ់"[72] របស់គាត់ មានសម្បទាគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យទៅលើអំពីឧក្រិដ្ឋរបស់គាត់បាន ព្រមទាំងនិទណ្ឌភាព *ជាក់ស្ដែង* (*de facto*) ចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវទទួលខុសត្រូវ។

---

[68] អនុសញ្ញាទីក្រុងហ្សឺណែវ ស្ដីពីការធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពរបួស និងជំងឺរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងសមរភូមិ, 75 UNTS 31 ("GC I")។ អនុសញ្ញាទីក្រុងហ្សឺណែវ ស្ដីពីការធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពរបួស ជំងឺ និងការលិចកប៉ាល់របស់កងកម្លាំងប្រដាប់អាវុធនៅក្នុងសមុទ្រ 75 UNTS 85 ("GC II"); អនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធនឹងការព្យាបាលឈ្លើយសឹក, 75 UNTS 135 ("GC III")។ អនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធនឹងការការពារជនស៊ីវិល ក្នុងពេលមានសង្គ្រាម 75 UNTS 287 ("GC IV") (ជារួមហៅថា "អនុសញ្ញាទីក្រុងហ្សឺណែវ")។

[69] អនុសញ្ញាស្ដីពីការការពារ និងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, 78 UNTS 277 ("អនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍")។

[70] លក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, 2187 UNTS 90។

[71] GC I, *ជើងទំព័រខាងលើ លេខ ៦៨*, មាត្រា 49, GC II, *ជើងទំព័រខាងលើ លេខ ៦៨*, មាត្រា ៥០, GC III, *ជើងទំព័រខាងលើ លេខ68*, មាត្រា ១២៩, GC IV, *ជើងទំព័រខាងលើ លេខ ៦៨* មាត្រា ១៤៦។ អនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, *ជើងទំព័រខាងលើ លេខ ៦៩*, មាត្រា VI; លក្ខន្តិកៈទីក្រុងរ៉ូម, *ជើងទំព័រខាងលើ លេខ ៧០*, បុព្វកថា, បុព្វកថា ទីប្រាំ។

[72] ឯកសារ E1/14.1 ប្រតិចារឹក, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១, នៅត្រង់ 13.51.17 [នួន ជា]។

## ខ) ការវាយប្រហាជាបុគ្គលដោយគ្មានមូលដ្ឋានទៅលើចៅក្រម Lavergne មិនបានបង្ហាញពីភាពលម្អៀងណាមួយឡើយ

28. នួន ជា បានចោទប្រកាន់ថា ចៅក្រម Lavergne មិនបានអនុវត្តតាម "សុច្ចរិតភាពផ្នែកសីលធម៌របស់ចៅក្រម"[73] ហើយបានឈានដល់ "សេចក្តីសន្និដ្ឋានដ៏កំសាក"[74] នៅពេលដែលគាត់មិនបានលើកលែងបទចោទប្រឆាំងនឹង នួន ជា។ នួន ជា បានអះអាងថា ដោយសារតែចៅក្រម Lavergne ជាមតិភាគតិចក្នុងសេចក្តីសម្រេចលើសាក្សីស្លាពរ[75] ដោយគាត់បានខ្វែងយោបល់គ្នាជាមួយសេចក្តីសម្រេចរបស់សហការីគាត់ គឺចៅក្រមកម្ពុជា ក្នុងការមិនកោះហៅសាក្សី ហេង សំរិន មកផ្តល់សក្ខីកម្មនោះ គាត់មានកាតព្វកិច្ចត្រូវធ្វើការលើកលែងបទចោទទាំងអស់។ ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានសីលធម៌ ឬចំណេះដឹងទេ។ ភាគីមួយមិនអាចស្នើសុំប្រកបដោយសីលធម៌ក្នុងការប្តឹងជំទាស់ចៅក្រមមួយរូប តាមរយៈការចោទប្រកាន់ពីភាពលម្អៀង ដោយគ្រាន់តែពួកគេចាញ់ក្តីនោះឡើយ។ ភស្តុតាងក្នុងសំណុំរឿង ០០២/០១ មានច្រើនហូរហៀរ។ ប្រសិនបើ នួន ជា ជឿជាក់ពិតប្រាកដថា ភស្តុតាងមិនគ្រប់គ្រាន់ ហើយតម្រូវឲ្យមានការលើកលែងបទចោទនោះ គាត់អាចធ្វើការជំទាស់ចំពោះការផ្តន្ទាទោសចំពោះរូបគាត់នៅដំណាក់កាលប្តឹងសាទុក្ខ។ ការដែល នួន ជា ជ្រើសរើសយកវិធីសាស្ត្រប្តឹងជំទាស់ចៅក្រម ដោយចោទប្រកាន់ពីភាពកំសាកនោះ គ្រាន់តែជាការបង្ហាញពីការមិនមានទំនុកចិត្តចំពោះទឡ្ហីករណ៍របស់គាត់ផ្ទាល់តែប៉ុណ្ណោះ។

29. មិនមានចំណុចណាមួយ ទាំងនៅក្នុងសារណា ឬនៅក្នុងសវនាការ ដែលមេធាវីការពារក្តី នួន ជា ធ្លាប់បានចង្អុលបង្ហាញពីអង្គហេតុដែល ហេង សំរិន អាចផ្តល់សក្ខីកម្ម ដែលអាចនាំទៅដល់ការលើកលែងបទចោទនានាប្រឆាំងនឹង នួន ជា នោះឡើយ។ ប៉ុន្តែ ភស្តុតាងដែលពួកគេបានចង្អុលបង្ហាញ បានត្រឹមតែបំពេញបន្ថែមទៅលើភស្តុតាងនៃពិរុទ្ធភាពដ៏ច្រើនលើសលប់របស់គាត់តែប៉ុណ្ណោះ។ ការដែល ហេង សំរិន បាននិយាយប្រាប់អ្នកនិពន្ធ Ben Keirnan ថា នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា បាននិយាយប្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឲ្យ "កម្ចាត់" ទាហាន លន់ នល់ គឺគ្រាន់តែជាការបំពេញបន្ថែមទៅលើភស្តុតាងស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់អតីត

[73] ឯកសារ E314/6 បណ្តឹងជំទាស់ចៅក្រម, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១៣២។

[74] ដូចជើងទំព័រខាងលើ។

[75] ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ ១៣០។

អ្នករដ្ឋការ លន់ នល់ ប៉ុណ្ណោះ ដោយសារតែក្នុងបរិបទនេះ នៅពេលដែល នួន ជា និយាយថា "កម្ចាត់" គឺពាក្យនេះត្រូវបានគេយល់ថាជាបញ្ជាឱ្យសម្លាប់។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងសវនាការ ដោយសាក្សីអ្នកជំនាញ Stephen Heder ដែលផ្តល់សក្ខីកម្មថាពាក្យ "កម្ចាត់" ក្នុងបរិបទនេះគឺ "ធ្វើឱ្យបាត់ បំបាត់ចោល"[76]។ ទឡ្ហីករណ៍ដែលថា ហេង សំរិន នឹងអាចផ្តល់ភស្តុតាងអត្តចរិតដ៏សំខាន់ ដែលអាចលុបលាងខ្លួន នួន ជា បាន គឺរិតតែចម្លែកថែមទៀត។ មេធាវីការពារក្តីមិនដែលពន្យល់ថា ផ្អែកលើមូលដ្ឋានអ្វីដែលពួកគេរំពឹងថា ហេង សំរិន ដែល នួន ជា ចោទប្រកាន់ថាបានចូលដៃជើងជាមួយបច្ចាមិត្តបរទេស មកប្រឆាំងនឹងរូបគាត់ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតនោះ នឹងអាចផ្តល់ភស្តុតាងវិជ្ជមានអំពីអត្តចរិតរបស់ នួន ជា នោះ។ ទឡ្ហីករណ៍នេះគឺជាល្បែងបាយឡុកបាយឡ យ៉ាងច្បាស់។

### គ) មេធាវីការពារក្តីមិនបានបំពេញតាមលក្ខខណ្ឌសម្រាប់បង្ហាញពីភាពលម្អៀង ដោយផ្អែកលើសេចក្តីសម្រេចដែលធ្វើឱ្យមានការប៉ះពាល់នាពេលកន្លងមក

30. សហព្រះរាជអាជ្ញាលើកឡើងថា ក) ការយល់ឃើញរបស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne នៅក្នុងសាលក្រមសំណុំរឿង ឌុច និង ខ) ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមរបស់ខ្លួនលើបញ្ហាអង្គហេតុដែលអាចទាក់ទងចំពោះសំណុំរឿង ០០២/០២ នោះ មិនបង្ហាញពីការស្តែងចេញនូវភាពលម្អៀងចំពោះសំណុំរឿង ០០២/០២ ឡើយ។ មូលដ្ឋានទាំងនេះ នឹងត្រូវលើកយកមកពិភាក្សាជាបន្តបន្ទាប់។

#### (១) ការយល់ឃើញរបស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne នៅក្នុងសំណុំរឿង ០០១

31. នួន ជា អះអាងថា ការយល់ឃើញផ្នែកអង្គហេតុមួយចំនួនរបស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne នៅក្នុងសាលក្រមសំណុំរឿង ០០១ បង្ហាញពីការស្តែងចេញនូវភាពលម្អៀងចំពោះសំណុំរឿង ០០២/០២។ ជាលទ្ធផល នួន ជា បានលើកទឡ្ហីករណ៍ថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne គួរត្រូវបានដកចេញពីតួនាទី ដោយផ្អែកលើមូលដ្ឋាន

[76] ឯកសារ E1/224.1 ប្រតិចារឹក, ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣, Stephen Heder, 15.15.32 ដល់ 15.19.30។

ថា អ្នកសង្កេតការណ៍ដែលមានហេតុផលម្នាក់ នឹងមិនជឿជាក់ថា ចៅក្រមទាំងនេះអាចធ្វើការសម្រេចចំពោះបញ្ហាតែមួយដោយឥតលម្អៀងនៅក្នុងសំណុំរឿង ០០២/០២ បានឡើយ។ សហព្រះរាជអាជ្ញាសូមលើកឡើងថា លក្ខខណ្ឌសម្រាប់ការបង្ហាញពីការស្តែងចេញនូវភាពលម្អៀង មិនត្រូវបានបំពេញឡើយ ហើយទឡ្ហីករណ៍របស់ នួន ជា គួរត្រូវបានបដិសេធទាំងស្រុងតែម្តង[77]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបដិសេធនាកន្លងមកចំពោះបណ្តឹងប្រហាក់ប្រហែលគ្នា ដែលពាក់ព័ន្ធដល់ការប្តឹងជំទាស់ចៅក្រមក្នុងសំណុំរឿង ០០២ មុនពេលមានការបំបែកកិច្ចដំណើរការនីតិវិធី[78]។

32. ចំណុចចម្បងនៃទឡ្ហីករណ៍របស់ នួន ជា គឺផ្អែកលើការបកស្រាយដោយខុសឆ្គងចំពោះពាក្យ "បុរេវិនិច្ឆ័យលើពិរុទ្ធភាព"[79]។ ការលើកឡើងថា "មិនមានភាពចាំបាច់ដែលចៅក្រមត្រូវមានបុរេវិនិច្ឆ័យលើគ្រប់សមាសធាតុ និងរាល់សមាសធាតុនីមួយៗ នៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ"[80] មិនមែនជាច្បាប់ដែលនៅជាធរមានឡើយ[81]។ ដើម្បីគាំទ្រដល់ការបកស្រាយរបស់ខ្លួន មេធាវីការពារក្តី បានដកស្រង់រឿងក្តី *Poppe* និងមតិយោបល់ជំទាស់របស់ចៅក្រម Buergenthal ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៃមតិប្រឹក្សារបស់តុលាការយុត្តិធម៌អន្តរជាតិ ស្តីពី *ផលវិបាកផ្លូវច្បាប់នៃការកសាងជញ្ជាំងក្នុងដែនដីប៉ាឡេស្ទីនដែលបានកាន់កាប់* ។ នួន ជា បានលើកឡើងដោយមិនត្រឹមត្រូវនូវអង្គច្បាប់ក្នុងរឿងក្តី *Poppe* [82]ដោយលុបចេញពីសារណារបស់គាត់នូវ "លក្ខណាវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ ហើយប្រសិនបើដូច្នេះ ថាតើម្ចាស់បណ្តឹង ដោយហួសពីវិមតិសង្ស័យ ពិតជាមានពិរុទ្ធភាព ឬអត់ ក្នុងការប្រព្រឹត្តិបទល្មើសបែបនេះ" ដែលនឹងតម្រូវឱ្យមាន ដើម្បីធ្វើបុរេវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ[83]។ លើសពីនេះទៀត មតិយោបល់ជំទាស់របស់ចៅក្រម Buergenthal ក្នុងរឿងក្តី *ជញ្ជាំងប៉ាឡេស្ទីន* កើតឡើងនៅក្នុងបរិបទនយោបាយដែលមានការចោទប្រកាន់យ៉ាងខ្លាំង ដោយនេះជាមតិយោបល់ជំទាស់តែមួយគត់

---

[77] សូមមើល កថាខណ្ឌ ៦ ខាងលើ។

[78] សូមមើល ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់ ឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ ៥*។

[79] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៣០។

[80] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៣០, ១១៦។

[81] *សូមមើល កថាខណ្ឌ ១២, ខាងលើ*; សាលក្រម រឿងក្តី Poppe, *ជើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៨។

[82] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១១៦។

[83] សាលក្រម រឿងក្តី *Poppe, ជើងទំព័រខាងលើ លេខ* ៣០ នៅត្រង់កថាខណ្ឌ ២៦, ២៨។

ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ១៥ រូប[84]។ ហេតុដូច្នេះ គួរតែផ្តល់តម្លៃតិចតួចបំផុតចំពោះមតិយោបល់ជំទាស់នេះ។

33. នួន ជា ព្យាយាមធ្វើឱ្យទឡ្ហីករណ៍របស់គាត់ខុសគ្នាទៅនឹងបណ្តឹងជំទាស់លើកទីមួយរបស់គាត់[85] ដោយបញ្ជាក់ថា "ការផ្តោតអារម្មណ៍" ថ្មីរបស់គាត់ គឺទៅលើការសម្រេចលើអង្គហេតុ ដែលបានធ្វើឡើងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១[86]។ គាត់បានអះអាងថា ការសម្រេចលើអង្គហេតុ ជាពិសេសពាក់ព័ន្ធនឹង៖ ១) ការសម្លាប់នៅ ស ២១, ២) លទ្ធភាពនៃការដោះលែងពី ស ២១, ៣) ការចោទប្រកាន់ពី "គោលនយោបាយកម្ទេច", ៤) ការសួរចម្លើយ, ៥) ការធ្វើទារុណកម្ម និង ៦)ការសម្លាប់ បានបង្ហាញថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne បានធ្វើបុរេវិនិច្ឆ័យលើបញ្ហាដែលចាំបាច់ត្រូវតែសម្រេចថ្មីនៅក្នុងសំណុំរឿង ០០២/០២[87]។

34. នួន ជា បានលើកឡើងដោយមិនត្រឹមត្រូវថា ការយល់ឃើញនៅក្នុងសំណុំរឿង ០០១ "តាមពិតអាចឈានទៅដល់ការបង្ហាញនូវការស្តែងចេញនូវភាពលម្អៀង ដែលមិនអាចទទួលយកបាន បើទោះបីជាពួកគេមិនបានបង្ហាញបុរេវិនិច្ឆ័យចំពោះសមាសធាតុទាំងអស់ និងសមាសធាតុនីមួយៗនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក៏ដោយ"[88]។ មានការកំណត់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិថា តម្រូវឱ្យមានបុរេវិនិច្ឆ័យចំពោះសមាសធាតុទាំងអស់ និងសមាសធាតុនីមួយៗនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដើម្បីឈានទៅដល់ការស្តែងចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន[89]។ ត្រឹមតែការដែលថា ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne ក្នុងពេលកន្លងមក បានសម្រេចលើអង្គហេតុនៃបញ្ហាដែលអាចពាក់ព័ន្ធចំពោះសំណុំរឿង ០០២/០២ នឹងមិនអាចបង្ហាញថា

[84] *សូមមើល, ផលវិបាកផ្លូវច្បាប់នៃការកសាងជញ្ជាំងក្នុងដែនដីប៉ាឡេស្ទីនដែលបានកាន់កាប់* ("ជញ្ជាំងប៉ាឡេស្ទីន"), មតិជំទាស់របស់ចៅក្រម Buergenthal លើដីកាចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤, 2004 ICJ Rep. 7, 30 Jan 2004 ("មតិចៅក្រម Buergenthal") នៅត្រង់កថាខណ្ឌ ១១, ១៣។

[85] E54 បណ្តឹងជំទាស់បន្ទាន់ ប្រឆាំងចៅក្រមអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្តឹងជំទាស់លើកទីមួយ របស់មេធាវីការពារក្តី")។

[86] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១១៩។

[87] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ កថាខណ្ឌ ១២០។

[88] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ១១៧។

[89] សាលក្រម រឿងក្តី *Poppe, ជើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៨។

ពួកគាត់មិនអាចធ្វើការពិចារណាដោយមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យចំពោះបញ្ហានៅក្នុងសំណុំរឿងបច្ចុប្បន្ននោះឡើយ ដូច្នេះមិនមែនជាភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញពីការយល់ឃើញអំពីភាពលម្អៀងនោះឡើយ[90]។

35. នៅក្នុងរឿងក្តី *Popović* ជារឿងក្តីមួយដែលអាចប្រៀបធៀបបានផ្នែកអង្គហេតុនោះ បណ្តឹងជំទាស់ចិត្ត របស់ជនជាប់ចោទ សុំដកចៅក្រមមួយរូបចេញពីការសម្រេចលើបណ្តឹងសាទុក្ខរបស់គាត់ ត្រូវបានបដិសេធ[91]។ ជនជាប់ចោទបានលើកទឡ្ហីករណ៍ថា ចៅក្រមដែលធ្លាប់ជំនុំជម្រះលើរឿងក្តីចំនួនពីរកន្លងមក ដែលមានភាពពាក់ព័ន្ធគ្នាផ្នែកអង្គហេតុ បានធ្វើការវាយតម្លៃជាវិជ្ជមានរួចទៅហើយលើភាពអាចជឿជាក់បានរបស់សាក្សីគន្លឹះរបស់រដ្ឋអាជ្ញា។ ការវាយតម្លៃបែបនេះគឺពាក់ព័ន្ធទៅនឹងអង្គហេតុតែមួយយ៉ាងប្រាកដ ដែលនៅក្នុងអង្គហេតុនេះ ជនជាប់ចោទត្រូវផ្តល់សក្ខីកម្មនៅក្នុងរឿងក្តីបច្ចុប្បន្ន ហើយអង្គហេតុបែបនេះ បណ្តាលឲ្យមានការប្តឹងសាទុក្ខរបស់ជនជាប់ចោទ។ ជនជាប់ចោទបានលើកឡើងថា មានការស្តែងចេញនូវភាពលម្អៀងគ្រប់គ្រាន់សម្រាប់ការប្តឹងជំទាស់ចិត្ត។ ប្រធានតុលាការ ICTY បានសម្រេចថា ត្រូវអនុវត្តការសន្មតទុកជាមុននូវភាពមិនលម្អៀងរបស់ចៅក្រម នៅពេលដោះស្រាយទៅលើភស្តុតាងដែលបានមកពីកិច្ចដំណើរការនីតិវិធីលើកមុន ដោយមិនគិតថាតើ ចៅក្រម ក្នុងពេលកន្លងមក បានធ្វើការពិចារណាវិជ្ជមាន ឬអវិជ្ជមាន ទៅលើភាពអាចជឿជាក់បានរបស់ភស្តុតាងនោះទេ។ ដូច្នេះ ការដែលចៅក្រមបានធ្វើការពិចារណាក្នុងពេលកន្លងមកទៅលើភាពអាចជឿជាក់បានរបស់សាក្សី ពាក់ព័ន្ធអង្គហេតុតែមួយ ដែលជាបញ្ហានៅក្នុងបណ្តឹងសាទុក្ខ មិនមែនជាមូលដ្ឋានគ្រប់គ្រាន់ដែលតម្រូវឲ្យមានការដកចេញឡើយ[92]។ ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមលើកឡើងថា ទំនាក់ទំនងណាមួយរវាងការសម្រេចរបស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne នៅក្នុងសាលក្រមសំណុំរឿង ០០១ និងអង្គហេតុដែលត្រូវសម្រេចក្នុងសំណុំរឿង ០០២/០២ នឹងមិនអាចបង្កើតជាការយល់ឃើញពីភាពលម្អៀងទេ។

36. បន្ទាប់មក នួន ជា ព្យាយាមលើកប្តឹងតវ៉ាសាជាថ្មីចំពោះទឡ្ហីករណ៍នៅក្នុងបណ្តឹងជំទាស់ចិត្តលើកទីមួយរបស់គាត់ ដែលរួមមាន ធាតុផ្សំទូទៅសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាង

[90] ករណី នៃសាលក្រម Schwarzenberger, ដើងទំព័រខាងលើ លេខ ២៦ នៅត្រង់កថាខណ្ឌ ៤២។

[91] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត របស់*Popović, ជើងទំព័រខាងលើ លេខ* ៣៣។

[92] *ដូចជើងទំព័រខាងលើ* . នៅត្រង់កថាខណ្ឌ ៣, ៧-៨, ១០, ១២ [ដោយមានការគូសបញ្ជាក់បន្ថែម]។

ធ្ងន់ធ្ងរនៅ ស ២១ ដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ ដូច្នេះទើបអាចចាត់ទុកថាជាបុរេវិនិច្ឆ័យចំពោះបញ្ហាដ៏ចម្បងនៅក្នុងសំណុំរឿង ០០២/០២[93]។ ដោយបញ្ចូលតាមរយៈការយោងទៅលើចម្លើយតបកន្លងមករបស់ពួកគេ សហព្រះរាជអាជ្ញាសូមលើកឡើងថា នួន ជា មិនបានបង្ហាញថា "*លក្ខណវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់បង្កើតជាបទល្មើសព្រហ្មទណ្ឌ*"[94] ក្នុងនាមជនជាប់ចោទទាក់ទងនឹង ស ២១ ត្រូវបានបុរេវិនិច្ឆ័យ[95]។ ចំណុចនេះត្រូវបានឯកភាពនៅក្នុងបណ្តឹងជំទាស់តែម្តងនៅពេលដែល នួន ជា បានលើកឡើងថា "ភស្តុតាងនៅសល់ទាំងអស់ដែល ក.ស.ព ត្រូវបង្ហាញពីពិរុទ្ធភាពរបស់ នួន ជា គឺត្រូវភ្ជាប់គាត់ជាមួយ "ប្រព័ន្ធនៃការធ្វើទារុណកម្ម" នៅស ២១"[96]។ ដោយមិនគិតដល់ការដែលថាសហព្រះរាជអាជ្ញាមិនបានដាក់សំណើសុំសច្ចូទស្សន៍តុលាការអំពីអង្គហេតុដែលបានវិនិច្ឆ័យរួចពីសំណុំរឿង ០០១ មកក្នុងសំណុំរឿង ០០២/០២ ហើយដោយមិនមានបុរេវិនិច្ឆ័យចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ ឲ្យលើសពីវិមតិសង្ស័យ ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ពាក់ព័ន្ធនឹង ស ២១[97] នោះ នួន ជា ពិតជាមិនបានបំពេញតាមលក្ខខណ្ឌសម្រាប់ការស្តែងចេញនូវភាពលម្អៀងរបស់ ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម Lavergne។

(២) ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១

37. នួន ជា បានចោទប្រកាន់ថា ការសម្រេចរបស់ចៅក្រមក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹង *ក្នុងចំណោមនោះ* (*inter alia*) វចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា អត្ថិភាពនៃគោលនយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ការយោងទៅលើការវិភាគប្រជាសាស្ត្រ និង "ការពឹងផ្អែក" លើសាលក្រមសំណុំរឿង ០០១ ដើម្បីកំណត់និយមន័យ "កម្មេច" នឹងធ្វើឲ្យអ្នកសង្កេតដែលមានហេតុផល

---

[93] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១១៩, ១២១; ឯកសារ E54 បណ្តឹងជំទាស់លើកទីមួយ របស់មេធាវីការពារក្តី, *ជើងទំព័រខាងលើ លេខ* ៨៤ នៅត្រង់កថាខណ្ឌ ២៧-២៩។

[94] *សាលក្រម រឿងក្តី* Poppe, *ជើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៨ [ដោយមានការគូសបញ្ជាក់បន្ថែម]។

[95] ឯកសារ E55 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា ប្រឆាំងចៅក្រម, ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នៅត្រង់កថាខណ្ឌ ៩-១០។

[96] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១២១។

[97] សូមមើល កថាខណ្ឌ ១២ ខាងលើ។ *សាលក្រម រឿងក្តី* Poppe, *ជើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៨។

អាចចោទសួរពីអនាគតិរបស់ចៅក្រមក្នុងសំណុំរឿង ០០២/០២[98]។ គ្មានការសម្រេចណាមួយក្នុងចំណោមការសម្រេចទាំងនេះ ដែលអាចចាត់ទុកថាជាការសម្រេចទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ នួន ជា ចំពោះបទចោទណាមួយនៅក្នុងសំណុំរឿង ០០២/០២ ឡើយ។ អ្នកសង្កេតដែលមានហេតុផល ដែលដឹងពីផលប៉ះពាល់ ពីសនិទានភាព និងផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីរបស់សំណុំរឿង ០០២ នឹងមិនអាចយល់ឃើញថាមានភាពលម្អៀងរបស់ចៅក្រម ដោយសារតែការសម្រេចលើអង្គហេតុក្នុងសំណុំរឿង ០០២/០១ ដែលអាចពាក់ព័ន្ធចំពោះសំណុំរឿង ០០២/០២ ឡើយ។

38. *<u>វចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា</u>*៖ នួន ជា បានចោទប្រកាន់ថា ការសម្រេចដោយមាន "កំហុសធ្ងន់" និង "ការដកចេញដោយមិនសមហេតុផល" ដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងវចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា បានបង្ហាញពីការមិនបើកចិត្តឲ្យទូលាយចំពោះបញ្ហាដែលមានសារៈសំខាន់យ៉ាងខ្លាំង[99]។ ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានឡើយ។ ការដែលអង្គជំនុំជម្រះបានស្តាប់ភស្តុតាងទាំងអស់ ហើយបានពិចារណាលើទឡ្ហីករណ៍នៅចំពោះមុខខ្លួន ព្រមទាំងធ្វើការសម្រេចដែលប៉ះពាល់ដល់ជនជាប់ចោទ មិនមែនជាមូលដ្ឋានសម្រាប់ប្តឹងដិតចិត្តឡើយ[100]។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍បែបនេះ ទោះបីជាមិនសមហេតុផលយ៉ាងណាក៏ដោយ គួរតែត្រូវលើកតវ៉ានៅក្នុងបណ្តឹងសាទុក្ខឲ្យបានត្រឹមត្រូវ[101]។

39. *<u>អត្ថិភាពនៃគោលនយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍</u>*៖ ការសម្រេចទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មាននៅត្រង់ផ្នែកមួយដែលមានចំណងជើងថា "មូលដ្ឋានប្រវត្តិសាស្ត្រ" ក្នុងសាលក្រមសំណុំរឿង ០០២/០១[102]។ អង្គជំនុំជម្រះបានពន្យល់ថា "ភស្តុតាងដែលត្រូវបានពិភាក្សានៅក្នុងផ្នែកនេះ ត្រូវបានផ្តល់ក្នុងគោល

---

[98] ឯកសារ E314/6 បណ្តឹងដិតចិត្ត, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៧១។

[99] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៧៨-៨០។

[100] សូមមើល កថាខណ្ឌ ៩, ១១, ខាងលើ។ *Re J.R.L.* Decision, ជើងទំព័រខាងលើ លេខ ១៨ *នៅត្រង់ទំព័រ* ៣៥២។

[101] សូមមើល កថាខណ្ឌ ១៧ ខាងលើ។

[102] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("E313 សាលក្រមសំណុំរឿង ០០២/០១") នៅត្រង់កថាខណ្ឌ ៧៩, ១២៨-១៣១។

បំណងបង្ហាញអំពីបរិបទប្រវត្តិសាស្ត្រ និងអង្គហេតុនៃហេតុការណ៍ទាំងឡាយដែលស្ថិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក"[103]។ ចំណុចនេះមានភាពស្របជាមួយនឹងការបញ្ជាក់បំភ្លឺកន្លងមករបស់អង្គជំនុំជម្រះ៖

> តាំងពីពេលចាប់ផ្ដើមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានជម្រាបដល់ភាគីថា ភាគីអាចចាប់ផ្ដើមលើភស្តុតាងដែលពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំជាមូលដ្ឋាន ប៉ុន្តែអង្គជំនុំជម្រះនឹងពិនិត្យមើលតែលើការអនុវត្តគោលនយោបាយណាដែលពាក់ព័ន្ធសំណុំរឿង ០០២/០១ ប៉ុណ្ណោះ (ឧទាហរណ៍ ការផ្លាស់ទីលំនៅដោយបង្ខំ និងការសម្លាប់ខ្មាំង)[104]។

40. ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ការបញ្ញត្តិលើការរៀបអាពាហ៍ពិពាហ៍គឺជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ "ភស្តុតាងពាក់ព័ន្ធខ្លឹមសារ និងការអនុវត្តគោលនយោបាយស្ដីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងវិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺជាកម្មវត្ថុនៃសំណុំរឿង ០០២/០២"[105]។ ការយល់ឃើញថាមានគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយមិនបានកំណត់ថាតើគោលនយោបាយនេះត្រូវបានអនុវត្តនៅពេលណា និងនៅទីណា ហើយថាតើ នួន ជា ត្រូវទទួលខុសត្រូវជាបុគ្គលដែរឬយ៉ាងណាចំពោះការអនុវត្តគោលនយោបាយនេះ មិនអាចចាត់ទុកថាជាបុរេវិនិច្ឆ័យលើពិរុទ្ធភាពឡើយ។

41. *<u>ការយោងទៅលើការវិភាគប្រជាសាស្ត្រ</u>*៖ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចលើអង្គហេតុ ទាក់ទងនឹងការវិភាគប្រជាសាស្ត្រចំពោះរបបកម្ពុជាប្រជាធិបតេយ្យទេ។ កថាខណ្ឌដែល នួន ជា បានដកស្រង់គឺស្ថិតនៅក្នុងផ្នែក "ទិដ្ឋភាពទូទៅ" របស់សាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលគោលដៅនៃ

---

[103] *ដូចជើងទំព័រខាងលើ* នៅត្រង់ ជើងទំព័រ ១៩៥។

[104] *ដូចជើងទំព័រខាងលើ* នៅត្រង់ ជើងទំព័រ ២៨៧។ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីពីការដាក់បញ្ចូលនូវគោលនយោបាយទាំងប្រាំ ធ្វើជាមូលដ្ឋាន និងក្នុងគោលបំណងជាបរិបទ ត្រឹមថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១១៖ សូមមើល ឯកសារ E124/7 សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំធ្វើការពិចារណាឡើងវិញ លើលក្ខខណ្ឌនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី របស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងសារណាពាក់ព័ន្ធ និងឧបសម្ព័ន្ធ, ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១១ នៅត្រង់កថាខណ្ឌ ១១ [" មានការសម្រេចថា អង្គជំនុំជម្រះនៅផ្នែកសវនាការដំបូង នឹងធ្វើការពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងទៅនឹងគោលនយោបាយទាំងអស់ ពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"]។

[105] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ១៣០។

ផ្នែកនេះគឺដើម្បី "បង្ហាញដោយសង្ខេបនូវការចោទប្រកាន់ផ្នែកអង្គហេតុ ដែលចោទប្រកាន់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងសំណុំរឿង ០០២/០១ និងការចោទប្រកាន់ទាក់ទងបរិបទទូលាយ នៃការវាយប្រហារដែលក្នុងការវាយប្រហារទាំងនោះ គឺមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ"[106]។ ទឡ្ហីករណ៍របស់ នួន ជា បានមើលរំលងលើចំណុចដែលថា ចំនួននៃអ្នកស្លាប់ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នានា នឹងត្រូវត្រួតពិនិត្យក្នុងសំណុំរឿង ០០២/០២។ នួន ជា នឹងមានឱកាសបង្ហាញភស្តុតាងបន្ថែមទាក់ទងនឹងបញ្ហានេះ។ ចំពោះអ្នកសង្កេតដែលមានហេតុផល ការដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការវិភាគប្រជាសាស្ត្រចំពោះរបបកម្ពុជាប្រជាធិបតេយ្យ មិនបានបង្ហាញថាមានការយល់ឃើញពីភាពលម្អៀងនោះឡើយ។

42. *<u>ការពឹងផ្អែកលើសំណុំរឿង ០០១ ដើម្បីកំណត់និយមន័យ "កម្ទេច"</u>*៖ ការយោងទៅលើពាក្យ "កម្ទេច" គឺស្ថិតនៅត្រង់ផ្នែក "មូលដ្ឋានប្រវត្តិសាស្ត្រ" នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើប្រភពជាច្រើនដើម្បីកំណត់និយមន័យ "កម្ទេច" នេះ។ ភស្តុតាងទទួលបានពីសាលក្រម ឌុច ត្រូវបានដកស្រង់រួមជាមួយសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ ដែលត្រូវបានផ្តល់នៅក្នុងសំណុំរឿង ០០២/០១[107]។ អង្គជំនុំជម្រះសាលាដំបូងមិនបានពឹងផ្អែកលើសាកក្រម ឌុច ដើម្បីបង្ហាញពីសមាសធាតុនៃបទឧក្រិដ្ឋ ឬពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ។ ការយោងទៅសាលក្រមមុននៅត្រង់ជើងទំព័រត្រឹមតែពីរក្នុងសាលក្រមដែលមានទំហំ ៦០០ ទំព័រ រួមជាមួយការយោងទៅភស្តុតាងមួយចំនួន បើទោះបីជាមានកំហុសឆ្គងក៏ដោយ ក៏មិនអាចបង្ហាញថា ចៅក្រមមិនអាចប្រើប្រាស់ "ការពិចារណាមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យ" នៅក្នុងសវនាការនៃសំណុំរឿង ០០២/០២ ដែរ[108]។

43. ជារួមមក បញ្ហាសំខាន់ជាគន្លឹះមិនមែនត្រង់ថាតើ ចៅក្រមនឹងដោះស្រាយបញ្ហាតែមួយនៅក្នុងសំណុំរឿង ០០២/០២ តាមវិធីសាស្ត្រដូចគ្នា ឬមិនដូចគ្នា នឹងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីសម្រេចក្នុងសំណុំរឿង ០០២/០១ឡើយ។ ត្រឹមតែអាចមានឱកាស ឬអាចមានលទ្ធភាព ដែលចៅក្រមនឹងសម្រេចលើបញ្ហាក្នុងសំណុំរឿង ០០២/០២ តាមវិធីសាស្ត្រដូចគ្នានឹងអ្វីដែលបានធ្វើក្នុងសាលក្រមមុន មិនអាច

---

[106] E313 សាលក្រមសំណុំរឿង០០២/០១ *ជើងទំព័រខាងលើ លេខ* 102 នៅកថាខណ្ឌ168 [ដោយមានការគូសបញ្ជាក់បន្ថែម]។

[107] *ដូចជើងទំព័រខាងលើ*. នៅត្រង់កថាខណ្ឌ 2014, ជើងទំព័រ 326, 330។

[108] សូមមើល កថាខណ្ឌ 6 ខាងលើ។

ជាមូលដ្ឋានសម្រាប់ការប្ដឹងជំទាស់ចិត្តបានឡើយ[109]។ អ្វីដែលត្រូវបង្ហាញ ហើយដែល នួន ជា មិនបាន បង្ហាញ គឺថា ចៅក្រម ដោយបានចូលរួមជំនុំជម្រះក្នុងរឿងក្ដីកន្លងមក នឹង "ប្រើប្រាស់ការពិចារណា ដែលមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យចំពោះបញ្ហានៅក្នុងរឿងក្ដីបច្ចុប្បន្ន"[110]។ ដូចដែលបានសង្ខេប ដោយអង្គជំនុំជម្រះសាលាដំបូង "បុរេវិនិច្ឆ័យចំពោះសេចក្ដីសម្រេចមួយចំនួន នៅពេលដែលបាន បង្ហាញតាមរយៈមតិរបស់ចៅក្រម នឹងមិនអាចចាត់ទុកថាជាភាពលម្អៀងឡើយ"[111]។

ឃ) មេធាវីការពារក្ដីមិនបានបំពេញតាមលក្ខខណ្ឌ ដើម្បីបង្ហាញពីភាពលម្អៀង ផ្អែកលើការយល់ ឃើញកន្លងមកអំពីទម្រង់នៃការទទួលខុសត្រូវរបស់សហឧក្រិដ្ឋកម្មរួម

44. នួន ជា បានអះអាងថា ការយល់ឃើញកន្លងមកអំពីអត្ថិភាព ការបង្កើត និងការវិវត្តន៍របស់គោល នយោបាយសហឧក្រិដ្ឋកម្មរួម ដែលត្រូវចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ គឺជា "បញ្ហាយ៉ាង សំខាន់ទាក់ទងនឹងពិរុទ្ធភាព" របស់ជនជាប់ចោទ ហើយដូច្នេះ បញ្ហាអង្គហេតុទាំងនេះត្រូវតែបង្ហាញជា ថ្មីនៅក្នុងសំណុំរឿង ០០២/០២ ទោះបីជាត្រូវបានសម្រេចរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ក៏ ដោយ[112]។ គាត់អះអាងថា ការយល់ឃើញមួយចំនួន ដែលមាននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលា ដំបូង អាចចាត់ទុកថាជាបុរេវិនិច្ឆ័យលើបញ្ហាទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ ឬក៏ជាទស្សនៈដែលបង្កើតទុកជាមុន ដោយមិនផ្ដល់ផលប្រយោជន៍ដល់ខាងមេធាវីការពារ ក្ដី ដែលចំណុចនេះនឹងជាការស្ដែងចេញនូវភាពលម្អៀង[113]។ ការលើកឡើងរបស់គាត់គឺថា បុរេវិនិច្ឆ័យ

[109] *Re J.R.L., ជើងទំព័រខាងលើ លេខ* ១៨ នៅត្រង់ទំព័រ ៣៥២។

[110] *ដូចជើងទំព័រខាងលើ*។

[111] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្ត ឆ្នាំ ២០១១, *ជើងទំព័រខាងលើ លេខ ៥* នៅត្រង់កថាខណ្ឌ ១៥ ដកស្រង់ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្ត របស់ *Karemera, ជើងទំព័រខាងលើ លេខ* ២២ នៅត្រង់កថាខណ្ឌ ១៥ ["លទ្ធភាពដែលថា ដោយ សារតែបានធ្វើការសម្រេចកន្លងមកទៅលើបញ្ហាពាក់ព័ន្ធ លើអង្គសេចក្ដីនោះ ទើបចៅក្រម Byron និងចៅក្រម Kam បានធ្វើបុរេ វិនិច្ឆ័យក្នុងការ អនុវត្តច្បាប់ និងវាយតម្លៃលើអង្គហេតុក្នុងលក្ខណៈដូចគ្នា មិនគ្រប់គ្រាន់ឡើយ ក្នុងបញ្ហាអង្គច្បាប់នៃការផ្លាស់ប្ដូរការ សន្មតទុកជាមុននៃភាពមិនលម្អៀង"]។

[112] ឯកសារ E314/6 បណ្ដឹងជំទាស់ចិត្ត, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១០០។

[113] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៩៣។

របស់ចៅក្រម ដែលកើតចេញពីសាលក្រមសំណុំរឿង ០០២/០១ នឹងជាការស្តែងចេញនូវភាពលម្អៀង ដែលមិនអាចទទួលយកបាន ដូច្នេះ ចៅក្រមគួរត្រូវបានដកចេញពីតួនាទី[114]។

45. សហព្រះរាជអាជ្ញាទទួលស្គាល់ហើយថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ជាការមិនអាចទទួលយកបាន ដែលអង្គជំនុំជម្រះសាលាដំបូងបានទាញយកការសន្និដ្ឋានអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បញ្ចូលទៅក្នុងការជំនុំជម្រះនានានៅពេលអនាគត មុនពេលដែលសាលក្រមសំណុំរឿង ០០២/០១ ចូលជាស្ថាពរ[115]។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ភាពដូចគ្នានៃភស្តុតាងមួយចំនួន ប៉ុន្តែបានសង្កត់ធ្ងន់ថា ភាពដូចគ្នានេះមិនអាចត្រូវបានពង្រីកទៅដល់ការយល់ឃើញនានាឡើយ ហើយសមាសធាតុអង្គហេតុដូចគ្នានៅក្នុងសំណុំរឿងទាំងអស់ដែលទទួលបានពីសំណុំរឿង ០០២ ចាំបាច់ត្រូវតែបង្ហាញសាជាថ្មី[116]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបន្ថែមទៀតថា នៅពេលនេះ "ខ្លួនអាចត្រឹមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនប្រើប្រាស់ការយល់ឃើញនៅក្នុងសំណុំរឿង ០០២/១ ដែលនឹងបង្ហាញយ៉ាងច្បាស់ថា ជាការសន្និដ្ឋានពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់សហជនជាប់ចោទទាក់ទងទៅនឹងបទចោទដែលត្រូវវិនិច្ឆ័យនៅក្នុងសំណុំរឿងបន្តបន្ទាប់"[117]។ ជាដំបូង សហព្រះរាជអាជ្ញាសូមលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើការយល់ឃើញបែបនេះទេ ហើយការយល់ឃើញនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង មិនអាចចាត់ទុកថាជាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ពាក់ព័ន្ធនឹងបទចោទដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ទេ។ ដូច្នេះនឹងមិនមានការបង្ហាញឲ្យឃើញពីការលម្អៀងជាក់ស្តែង ឬការយល់ឃើញពីភាពលម្អៀង ផ្អែកលើការសម្រេចកន្លងមករបស់ចៅក្រម ចំពោះអត្ថិភាព និងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម ដែលមាននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ឡើយ។

---

[114] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ១០០។

[115] ឯកសារ E301/9/1/1/3 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំរបស់ ខៀវ សំផន ប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ នៅត្រង់កថាខណ្ឌ ៨៥។

[116] *ដូចជើងទំព័រខាងលើ*។

[117] *ដូចជើងទំព័រខាងលើ*។

46. ដើម្បីបង្កើតមូលដ្ឋានសម្រាប់ការប្តឹងជំទាស់ សាលក្រមពីមុនត្រូវតែមានការយល់ឃើញ "ដែលបុរេវិនិច្ឆ័យជាក់ស្តែងទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ"[118]។ បុរេវិនិច្ឆ័យបែបនេះមិនកើតមានឡើង ដោយគ្រាន់តែចៅក្រមបានសម្រេចទាក់ទងនឹងបញ្ហានានានៅក្នុងសាលក្រមលើកមុននោះឡើយ។ ដើម្បីបង្ហាញពីបុរេវិនិច្ឆ័យ ការយល់ឃើញទាំងនេះចាំបាច់ត្រូវមានការពាក់ព័ន្ធនឹងការសម្រេច "លើលក្ខណវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់បង្កើតជាបទល្មើសព្រហ្មទណ្ឌ ហើយ [...] ថាតើដោយហួសពីវិមតិសង្ស័យ ម្ចាស់បណ្តឹងពិតជាមានពិរុទ្ធភាព ឬអត់ ចំពោះការប្រព្រឹត្តិបទល្មើសបែបនេះ"[119]។

### ង) មេធាវីការពារក្តីមិនបានបំពេញលក្ខខណ្ឌដើម្បីបង្ហាញពីភាពលម្អៀង ផ្អែកលើការពឹងផ្អែកលើសក្ខីកម្មអ្នកជំនាញ

47. នួន ជា បានលើកទឡ្ហីករណ៍ថា ចៅក្រមបានបង្ហាញពីកង្វះសុច្ចរិតភាពវិជ្ជាជីវៈ ដោយពឹងផ្អែកហួសហេតុទៅលើសក្ខីកម្មរបស់អ្នកជំនាញ[120]។ ដូចដែលគាត់បានទទួលស្គាល់ នីតិវិធីប្តឹងជំទាស់មិនមែនជាទីកន្លែងដើម្បីវាយតម្លៃលើមូលដ្ឋានផ្លូវច្បាប់របស់ការពឹងផ្អែកហួសហេតុពេកទៅលើសក្ខីកម្មអ្នកជំនាញតាមដែលចោទប្រកាន់ឡើយ[121]។ វិធាន ៣១(ខ) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុំជម្រះស្វែងរកសក្ខីកម្មអ្នកជំនាញ និងធ្វើការវាយតម្លៃទៅលើព័ត៌មានដែលបានផ្តល់ឲ្យនោះ[122]។ ត្រឹមតែការដែលសាលក្រមសំណុំរឿង ០០២/០១ រួមបញ្ចូលការយោងមួយចំនួនទៅសក្ខីកម្មអ្នកជំនាញនោះ មិនគ្រប់គ្រាន់សម្រាប់បង្ហាញពីការស្តែងចេញនូវភាពលម្អៀង នាពេលបច្ចុប្បន្ន ឬអនាគតទេ ដោយសារតែអ្នកសង្កេតដោយមានហេតុផល ហើយទទួលបានព័ត៌មានគ្រប់គ្រាន់អំពីវិធានស្តីពីនីតិវិធី និងភស្តុតាងជាធរមាន នឹងមិនអាចយល់ឃើញពីភាពលម្អៀងឡើយ។

---

[118] *សាលក្រម រឿងក្តី Poppe, ដើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៦។

[119] *សាលក្រម រឿងក្តី Poppe, ដើងទំព័រខាងលើ លេខ* ២៩ នៅត្រង់កថាខណ្ឌ ២៨។

[120] ឯកសារ E314/6 បណ្តឹងជំទាស់, *ដើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ១២៩។

[121] ដូចជើងទំព័រខាងលើ។

[122] វិធានផ្ទៃក្នុង ៣១(ខ)។

ច) មេធាវីការពារក្តី មិនបានបំពេញតាមលក្ខខណ្ឌបង្ហាញពីភាពលម្អៀង ផ្អែកលើការប្រើប្រាស់ភាសា និងវណ្ណយុត្ត

48. នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង នួន ជា បានជំទាស់លើការប្រើប្រាស់ "គុណនាមស្រពិចស្រពិល" "អភន្តរៈសញ្ញាឌឺដង" "ការជ្រើសរើសប្រើប្រាស់អភន្តរៈសញ្ញាដើម្បីបង្ហាញអំពីមន្ទិលសង្ស័យចំពោះភស្តុតាង" និង "នាមប្រមាថមើលងាយ"[123] ដោយចោទប្រកាន់ថា ការប្រើប្រាស់បច្ចេកទេសភាសាអង់គ្លេសបែបបទនេះ បង្ហាញពីការយល់ឃើញដោយសមហេតុផលនូវភាពលម្អៀង នៅពេលដោះស្រាយបញ្ហាដែលជាចំណុចស្នូលនៃទ្រឹស្តីការពារខ្លួនរបស់គាត់ ដែលរួមមាន ការគំរាមកំហែងពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ គោលនយោបាយ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជាសកម្មភាព និងនយោបាយនៃរបប លន់ នល់ និងតួនាទីរបស់សម្តេចព្រះវរាជបិតានរោត្តម សីហនុ[124]។ សហព្រះរាជអាជ្ញាសូមលើកឡើងថា ការប្រើប្រាស់ភាសា និងវណ្ណយុត្ត ដែលអង្គជំនុំជម្រះសាលាដំបូង អនុម័តយកនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង មិនបានផ្ទុះបញ្ចាំងពីការមិនបើកចិត្តឱ្យទូលាយចំពោះភស្តុតាង ឬសារណាឡើយ ហើយក៏មិនអាចចាត់ទុកជាការស្តែងចេញនូវភាពលម្អៀងរបស់ចៅក្រម ដែលអាចបណ្តាលឱ្យមានបណ្តឹងជិតចិត្តឡើយ[125]។

49. មេធាវីការពារក្តីអះអាងថាជំទាស់ទៅនឹងភាសា និងវណ្ណយុត្ត ប៉ុន្តែ តាមពិតទៅ ពួកគេព្យាយាមជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅវិញ។ ដូចដែលបានពិភាក្សានៅក្នុងផ្នែកមុនមក ត្រឹមតែការដែលថាអង្គជំនុំជម្រះធ្វើការសម្រេចលើអង្គហេតុដែលប៉ះពាល់ដល់ នួន ជា នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង មិនអាចបង្ហាញពីអត្ថិភាពនៃការស្តែងចេញនូវភាពលម្អៀងឡើយ ព្រោះអង្គជំនុំជម្រះធ្វើការសម្រេចបែបនេះ បន្ទាប់ពីបានអនុវត្តច្បាប់ទៅលើភស្តុតាងដែលបានបង្ហាញនៅក្នុងពេលជំនុំជម្រះ[126]។ ហេតុដូច្នេះ បញ្ហាបែបនេះគួរលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ មិនមែននៅចំពោះមុខ

[123] ឯកសារ E314/6 បណ្តឹងជិតចិត្ត, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៦២។

[124] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៦២-៦៧។

[125] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៦២។

[126] *ដូចជើងទំព័រខាងលើ។* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, *ជើងទំព័រខាងលើ លេខ* ១០២ នៅត្រង់កថាខណ្ឌ ៣៨៥។

ក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលមិនបានទទួលបញ្ហាអង្គសេចក្តីទាក់ទងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។

50. ការប្រើប្រាស់ភាពស្រពិចស្រពិល ការឌឺដង អភន្តរៈសញ្ញា និងនាមប្រមាថមើលងាយ គឺជាការអនុវត្តទូទៅនៅក្នុងសាលក្រម។ ជាញឹកញាប់ សាលក្រមយោងទៅពាក្យពេចន៍ ដែលភាគីបានប្រើប្រាស់នៅក្នុងសារណាផ្ទាល់ខ្លួនរបស់ពួកគេ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក៏អនុវត្តបែបនេះដែរ។ បច្ចេកទេសក្នុងការប្រើប្រាស់ពាក្យ និងបែបបទនេះ ត្រូវបានប្រើប្រាស់សម្រាប់៖ ក) ចង្អុលបង្ហាញពីភាសាអត្ថនោម័តជាក់លាក់របស់ភាគីមួយ ដែលអង្គជំនុំជម្រះសាលាដំបូងព្យាយាមមិនធ្វើការសម្រេចលើអង្គហេតុ ឬ ខ) ជាទម្រង់នៃការសរសេរកាត់ចំពោះភាសាយោង ដែលឆ្លុះបញ្ចាំងពីការសម្រេចលើអង្គហេតុក្នុងពេលកន្លងមក ដោយអង្គជំនុំជម្រះក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

51. ការប្រើប្រាស់បច្ចេកទេសភាសា និងវណ្ណយុត្ត មានភាពសមស្របទាំងស្រុង នៅពេលដែលអង្គជំនុំជម្រះមិនចង់គាំទ្រ ឬបដិសេធទៅលើអត្ថន័យនៃភាសាអត្ថនោម័ត ដែលភាគីបានប្រើ។ ឧទាហរណ៍ មេធាវីការពារក្តីជំទាស់ទៅនឹងការប្រើប្រាស់អភន្តរៈសញ្ញា ទាក់ទងទៅនឹងពាក្យ "ខ្មាំង"[127]។ ការប្រើប្រាស់អភន្តរៈសញ្ញា ក្នុងករណីនេះ គឺគ្រាន់តែបង្ហាញថា នៅពេលប្រើប្រាស់ពាក្យ "ខ្មាំង" អង្គជំនុំជម្រះមិនគាំទ្រ ហើយក៏មិនអនុម័តយកនិយមន័យបែបអត្ថនោម័តរបស់ខ្មែរក្រហមនេះទេ។ វាជារឿងធម្មតាសម្រាប់អង្គជំនុំជម្រះក្នុងការប្រើប្រាស់អភន្តរៈសញ្ញា និងបច្ចេកទេសភាសាផ្សេងទៀត នៅពេលអង្គជំនុំជម្រះចាំបាច់ត្រូវពិភាក្សា ប៉ុន្តែចង់ដកខ្លួនឱ្យឆ្ងាយពីទម្រង់នៃទឡ្ហីករណ៍ជាក់លាក់ ឬការពណ៌នាអំពីអង្គហេតុដែលខ្លួនមិនបានធ្វើការសម្រេចលើអង្គហេតុ។ ឧទាហរណ៍ នៅក្នុងរឿងក្តីការបដិសេធមិនទទួលស្គាល់ Holocaust ដែលលេចធ្លោរ ស្តីពីបទចោទព្រហ្មទណ្ឌនៃការ "ផ្សព្វផ្សាយព័ត៌មានមិនពិត" តុលាការកំពូលកាណាដាប្រើប្រាស់អភន្តរៈសញ្ញាបាន ចំពោះពាក្យពេចន៍ដែលយល់ឃើញថាតំណាងឱ្យទស្សនៈ ឬមតិជាក់ស្តែង ឬបែបសម្មតិកម្ម[128]។ ប្រហាក់ប្រហែលគ្នានេះ តុលាការថ្នាក់តំបន់របស់សហរដ្ឋអាមេរិក បានផ្តល់យុត្តិកម្មយ៉ាងច្បាស់លាស់អំពីការប្រើប្រាស់អភន្តរៈសញ្ញាឌឺដង (ដែលហៅថា "ការដកស្រង់ភ័យខ្លាច") នៅពេលដែលយោងទៅលើ "ជំហរ" របស់ចុងចោទ ព្រោះចៅក្រមអង្គ

[127] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ៦៣។ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, *ជើងទំព័រខាងលើ លេខ* ១០២ នៅត្រង់កថាខណ្ឌ ៩០៨។

[128] *R តទល់នឹង Zundel*, 1992 2 SCC 731 (តុលាការកំពូល ប្រទេសកាណាដា) នៅត្រង់ទំព័រ ៧៥២-៧៥៣។

ជំនុំជម្រះសាលាដំបូងយល់ឃើញថា ការប្រើប្រាស់ពាក្យនេះ "គឺមិនមែនជាវិធីសាស្ត្រដ៏ល្អក្នុងការពណ៌នានូវទស្សនៈ ដែលចុងចោទបានលើកឡើងនៅក្នុងសារណារបស់ខ្លួន"[129]។

52. ការប្រើប្រាស់ភាសា និងបច្ចេកទេសវណ្ណយុត្ត មានសមស្របទាំងស្រុងដូចគ្នា ក្នុងទម្រង់នៃការសរសេរកាត់ចំពោះភាសាយោង ដែលឆ្លុះបញ្ចាំងពីការសម្រេចលើអង្គហេតុក្នុងពេលកន្លងមក ដោយអង្គជំនុំជម្រះ។ ឧទាហរណ៍ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងថា ខ្លួនមិនគាំទ្រដល់ "អត្ថន័យដែលចង្អុលបង្ហាញតាមរយៈការប្រើប្រាស់របស់ពួកខ្មែរក្រហមទៅលើពាក្យ "រំដោះ" ហើយអង្គជំនុំជម្រះសរសេរពាក្យនេះដោយដាក់ក្នុងអវតរណសញ្ញា ដើម្បីបង្ហាញជាពិសេសអំពីចេតនាមិនចង់ប្រើប្រាស់ពាក្យនេះ[130]។ ការដែលអង្គជំនុំជម្រះជ្រើសយកការមិនសរសេរជាជើងទំព័រចំពោះប្រយោគប្រហាក់ប្រហែលគ្នា បន្ទាប់ពីការប្រើប្រាស់អវតរណសញ្ញាម្តងៗរួចហើយនោះ គឺជាសេចក្តីសម្រេចលើការសរសេរជាទម្លាប់ ដែលជាយុត្តិកម្មសមស្រប ដោយសារតែទំហំ និងភាពស្មុគស្មាញនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ សរុបមក ការលើកឡើងរបស់មេធាវីការពារក្តីដែលថា ការប្រើប្រាស់ភាសា និងវណ្ណយុត្ត បានបង្ហាញពីភាពលម្អៀងជាក់ស្តែង ឬការយល់ឃើញពីភាពលម្អៀង មិនគ្រប់គ្រាន់តាមលក្ខណៈច្បាប់នៅក្នុងបរិបទនៃបណ្តឹងជិតចិត្តឡើយ។

## ៣. វចនាសម្ព័ន្ធ និងមុខងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនបានបង្ហាញពីភាពលម្អៀងជាក់ស្តែង ឬការយល់ឃើញពីភាពលម្អៀងឡើយ

53. អ.វ.ត.ក ស្ថិតនៅដាច់ដោយឡែកពីប្រព័ន្ធយុត្តិធម៌កម្ពុជាជារួម ដោយសារ អ.វ.ត.ក មិនត្រូវបានដាក់ឱ្យស្ថិតនៅក្នុងឋានានុក្រមនៃតុលាការធម្មតា ឬប្រើប្រាស់សិទ្ធិអំណាចដើម្បីត្រួតពិនិត្យលើតុលាការទាំងនោះឡើយ[131]។ ចៅក្រមរបស់ អ.វ.ត.ក រួមទាំងចៅក្រមជាតិផង ទទួលបានអភ័យឯកសិទ្ធិលើ "ដំណើរការច្បាប់" (រួមបញ្ចូលទាំងដំណើរការដាក់វិន័យ) ក្នុងពេលបំពេញតួនាទីរបស់ពួកគេ[132]។

---

[129] *United Latin Am. Citizens (Lulac) of Wisconsin តទល់នឹង Deininger*, 12-C-0185 (E.D. Wis. ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៣) នៅត្រង់ ១ (តុលាការ ថ្នាក់តំបន់សហរដ្ឋអាមេរិក)។

[130] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, *ជើងទំព័រខាងលើ លេខ* ១០១ នៅត្រង់កថាខណ្ឌ ៣៨៤។

[131]

[132] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២០(១)។

ដូច្នេះពួកគាត់នឹងមិនស្ថិតនៅក្រោមដំណើរការដាក់វិន័យធម្មតា សម្រាប់ចៅក្រមកម្ពុជា ក្នុងការបំពេញតួនាទីរបស់ពួកគាត់នៅ អ.វ.ត.ក ឡើយ។

54. ទឡ្ហីករណ៍ដែល នួន ជា បានលើកឡើងថា "សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមមាន អ្នកដែលត្រូវបានតែងតាំងបួនរូបដោយអង្គនីតិប្រតិបត្តិ"[133] គឺជាការខុសឆ្គង និងមិនមានមូលដ្ឋានឡើយ។ ចំណុចទីមួយ ទឡ្ហីករណ៍របស់មេធាវីការពារក្តីមិនបានគិតដល់ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានអនុម័តនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលក្នុងនោះរួមមានការផ្លាស់ប្តូរសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមិនទាន់ត្រូវបានអនុវត្តនៅឡើយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាធ្វើការឆ្លើយតប ផ្អែកលើច្បាប់ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលមេធាវីការពារក្តីបានដកស្រង់។

55. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាជិកចំនួនប្រាំបួនរូប[134] គឺព្រះមហាក្សត្រទ្រង់គង់ជាប្រធាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រមបីរូបទៀត ដែលជ្រើសរើសដោយចៅក្រមជាសមាជិក។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺគ្រាន់តែជាសមាជិកមួយរូបនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូច្នេះមិនមានសិទ្ធិអំណាចអ្វីទាំងអស់ក្នុងការតែងតាំងចៅក្រមជាតិបីរូប ដូច នួន ជា បានចោទប្រកាន់នោះឡើយ។ ផ្ទុយទៅវិញ មានតែព្រះមហាក្សត្រប៉ុណ្ណោះ ទើបមានសិទ្ធិតែងតាំងសមាជិកទាំងអស់នៃក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈព្រះរាជក្រឹត្យ ដោយសារទ្រង់គឺជាអ្នកធានាពីឯករាជ្យភាពរបស់តុលាការ[135]។

56. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមធ្វើសេចក្តីសម្រេច ផ្តល់អនុសាសន៍ទាក់ទងសកម្មភាពផ្សេងៗទៅព្រះមហាក្សត្រអំពីការតែងតាំង ការផ្ទេរ ការផ្អាកមុខងារ (ដាក់ស្តែង) ការព្យួរ និងការដកចេញពីឋានៈ

---

[133] ឯកសារ E314/6 បណ្តឹងជំទាស់, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៤៣, ជើងទំព័រ ៦៩។

[134] មាត្រា ២, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ("ច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម")។

[135] មាត្រា ១៣២ ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ ១៩៩៣។

និងការដកហូតឋានន្តរស័ក្តិ ពីចៅក្រម និងព្រះរាជអាជ្ញាកម្ពុជាទាំងអស់[136]។ ពាក់ព័ន្ធនឹងបញ្ហានៃការដាក់វិន័យ ដែលត្រូវអនុវត្តប្រឆាំងនឹងចៅក្រម និងព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើការកោះប្រជុំក្នុងទម្រង់ជាក្រុមប្រឹក្សាវិន័យ ហើយស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យលើថាតើការដាក់វិន័យនេះត្រូវធ្វើឡើងចំពោះចៅក្រម ឬព្រះរាជអាជ្ញា។ ក្នុងស្ថានភាពសន្ទតមួយ បើចៅក្រមជាតិត្រូវប្រឈមការដាក់វិន័យទាក់ទងនឹងការងាររបស់ពួកគាត់នៅតុលាការកម្ពុជាធម្មតា ពួកគាត់នឹងត្រូវប្រឈមមុខជាមួយក្រុមប្រឹក្សា ដែលក្នុងក្រុមប្រឹក្សានេះ សហព្រះរាជអាជ្ញាជាតិមិនមានតួនាទីអ្វីទាំងអស់។ ក្នុងករណីបែបនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនចូលរួមក្នុងកិច្ចប្រជុំឡើយ[137]។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវផ្អែកទៅលើសម្លេងឆ្នោតភាគច្រើនរបស់សមាជិកដែលមានវត្តមាន តាមរយៈការបោះឆ្នោតសម្ងាត់[138]។

57. ការព្រួយបារម្ភដែលថាចៅក្រមកំពុងកាន់តំណែងនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយដែលត្រូវបានតែងតាំងជាចៅក្រមនៅ អ.វ.ត.ក អាចមានឥទ្ធិពលដល់សេចក្តីសម្រេច ឬក៏ប្រើប្រាស់អំណាចដោយមិនត្រឹមត្រូវទៅលើចៅក្រមដទៃទៀតនៅ អ.វ.ត.ក គ្មានមូលដ្ឋានច្បាស់លាស់ឡើយ។ មាត្រាជាច្រើននៅក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានបង្ហាញច្បាស់ថា បែបបទ និងនីតិវិធីទាក់ទងនឹងការតែងតាំង ការផ្ទេរ ការផ្អាកមុខងារ (ជាក់ស្តែង) ការព្យួរ និងការដកចេញពីឋានៈ និងការដកហូតឋានន្តរស័ក្តិ ព្រមទាំងការដំឡើងថ្នាក់ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដូច្នេះមិនមានសមាជិកណាម្នាក់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចធ្វើសកម្មភាពតាមអំពើចិត្ត រំលោភបំពានទៅលើគោលការណ៍ និងវិធានការដែលមានចែងក្នុងច្បាប់ឡើយ។ លើសពីនេះទៀត ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានចែងទាក់ទងនឹងភាពមិនស៊ីសង្វាក់គ្នារវាងការងារតុលាការនៅ អ.វ.ត.ក និងតួនាទីនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[139]។ តាមពិតទៅ មុខងារពីរនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក និង អ.វ.ត.ក សម្រាប់មន្ត្រីជាន់ខ្ពស់កម្ពុជា ត្រូវបានប្រមើល

---

[136] ច្បាប់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, *ជើងទំព័រខាងលើ លេខ* ១៣២, មាត្រា ១១។

[137] *ដូចជើងទំព័រខាងលើ* មាត្រា ១២។

[138] *ដូចជើងទំព័រខាងលើ* មាត្រា ៩។

[139] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១០ ថ្មី ១១ ថ្មី និង ១៩។

មើលយ៉ាងច្បាស់នៅក្នុងក្របខណ្ឌច្បាប់ជាធរមាន ដើម្បីសម្របសម្រួលដល់ការផ្ទេរជំនាញ និងកសាងសមត្ថភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ជាតិ។

### ៤. លក្ខណៈពិតប្រាកដនៃបណ្តឹងជំទាស់ (បណ្តឹងដិតចិត្ត)

58. ការអះអាងរបស់ នួន ជា អាចយល់បានក្នុងន័យពិតប្រាកដ ដោយផ្អែកលើការអះអាងរបស់គាត់អំពី "ការស្អប់ខ្ពើម ... មនោគមន៍វិជ្ជារបស់គាត់"[140] ប្រទេស "អាណានិគម និងចក្រពត្តិ"[141] និង "Anglo-French" "ពាក់កណ្តាលអ្នកជំនាញ"[142] ចេតនារបស់គាត់ចង់យកគូសត្រូវផ្នែកនយោបាយរបស់គាត់មកធ្វើការជំនុំជម្រះ[143] និងបង្អាច់បង្អួចខ្លាំងរបស់គាត់[144] ហើយកំណត់ត្រាដែលមានស្រាប់ចាប់តាំងពីដើមដំបូងនៃកិច្ចដំណើរការនីតិវិធី បានបង្ហាញពីយុទ្ធសាស្ត្ររបស់គាត់ក្នុងការធ្វើឲ្យប៉ះពាល់ដល់ អ.វ.ត.ក ជាស្ថាប័នទាំងមូលតែម្តង[145] ព្រមទាំងធ្វើយ៉ាងណាឲ្យមនុស្សទាំងអស់ ទាំងកម្ពុជា និងបរទេស មិនឲ្យមានសម្បទាក្នុងការវិនិច្ឆ័យលើការប្រព្រឹត្តិរបស់គាត់។ បណ្តឹងដិតចិត្តនេះគ្រាន់តែជាការព្យាយាមមួយទៀតក្នុងការធ្វើឲ្យសាធារណជនយល់ច្រឡំ ហើយទាញចំណាប់អារម្មណ៍សាធារណជនចេញពីអំពើឧក្រិដ្ឋផ្ទាល់ខ្លួនរបស់គាត់ប៉ុណ្ណោះ។

## IV. សំណើសុំដំណោះស្រាយ

---

[140] ឯកសារ E314/6 បណ្តឹងដិតចិត្ត, *ជើងទំព័រខាងលើ លេខ* ២ នៅត្រង់កថាខណ្ឌ ៦៩។

[141] *ដូចជើងទំព័រខាងលើ* នៅត្រង់កថាខណ្ឌ ១២៩។

[142] *ដូចជើងទំព័រខាងលើ*។

[143] សូមមើល ជាឧទាហរណ៍ ឯកសារ E146.1 ដំរីងាប់យកចង្អេបាំង, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅត្រង់ទំព័រ ២ ["Where is Henry Kissinger?"]។ ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ នៅត្រង់កថាខណ្ឌ ២៣-២៦ ("បទដ្ឋានទស្សនៈរូម")។

[144] សូមមើល ជាឧទាហរណ៍ ឯកសារ E1/14.1 ប្រតិចារឹក, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅត្រង់ 13.59.43, 15.08.57 ["...ដើម្បីរំដោះមាតុភូមិខ្ញុំចេញពីអាណានិគមនិយម និងការឈ្លានពាន និងគៀបសង្កត់ដោយកងកម្លាំង ដោយពួកចោរដែលចង់លួចទឹកដី និងលុបបំបាត់ប្រទេសកម្ពុជាចេញពីពិភពលោក"]។

[145] សូមមើល ជាឧទាហរណ៍ ឯកសារ E146.1 ដំរីងាប់យកចង្អេបាំង, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅត្រង់ទំព័រ ៣ ["តុលាការនេះគឺរដ្ឋាភិបាល យ៉ាងច្រើនបំផុតគឺជាតុលាការឯករាជ្យបានត្រឹម ២ភាគ៥"]។ ឯកសារ E214 សេចក្តីសម្រេចលើកំហុសឆ្គងរបស់មេធាវីការពារក្តី នួន ជា, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ [និងរបៀបវារៈពាក់ព័ន្ធឯកសារ E214/2, E214/3, E214/4 និង E214/5]។

59. សម្រាប់សំអាងហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាសូមស្នើដោយសេចក្តីគោរពដល់ក្រុមប្រឹក្សាជំនុំជម្រះពិសេស មេត្តាបដិសេធបណ្តឹងជំទាស់របស់ នួន ជា ទាំងស្រុង ហើយសម្រេចលើបណ្តឹងនេះឲ្យបានឆាប់រហ័ស។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ | ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |